ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ









## របស់

## ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ២០០៨-២០១០

រៀបចំដោយក្រុមការងារយេនឌ័រក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សហការជាមួយគំរោង *ភាពជាដៃគូដើម្បីសមធម៌យេនឌ័រ* នៃក្រសួងកិច្ចការនារី

និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ

UNDP

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ

## របស់

## ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ២០០៨-២០១០

រៀបចំដោយក្រុមការងារយេនឌ័រក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សហការជាមួយគំរោង *ភាពជាដៃគូដើម្បីសមធម៌យេនឌ័រ* នៃក្រសួងកិច្ចការនារី

និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ

# មាតិកា


**បុព្វកថា** ---------- ៣

**សេចក្តីថ្លែងអំណរគុណ** ---------- ៤

**សេចក្តីផ្តើម** ---------- ៥

**ជំពូកទី ១ ស្ថានភាពយេនឌ័រនៅប្រទេសកម្ពុជា** ---------- ៧

១.១ ស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចរបស់ស្ត្រី ---------- ៧

១.២ ស្ត្រីនៅក្នុងទីផ្សារពលកម្ម ---------- ៧

១.៣ ស្ត្រីនៅក្នុងវិស័យកសិកម្ម ---------- ៨

១.៤ ស្ត្រី និងការអប់រំ ---------- ៨

១.៥ ស្ត្រី និងសុខភាព ---------- ៩

១.៦ អំពើហិង្សាលើស្ត្រី ---------- ៩

១.៧ ស្ត្រីនៅក្នុងនយោបាយ និងការធ្វើសេចក្តីសម្រេច ---------- ៩

**ជំពូកទី ២ ស្ថានភាពទូទៅនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** ---------- ១០

២.១ ប្រវត្តិក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ---------- ១០

២.២ ប្រវត្តិក្រុមការងារយេនឌ័រ ---------- ១១

២.៣ សមិទ្ធផលសម្រេចបាននាពេលកន្លងមក ---------- ១១

២.៤ បញ្ហាយេនឌ័រនៅក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ---------- ១៣

**ជំពូកទី ៣ ស្ថានភាពយេនឌ័រក្នុងវិស័យដីធ្លី និងសំណង់** ---------- ២០

៣.១ ការចុះបញ្ជីដីធ្លី និងការផ្តល់ប័ណ្ណកម្មសិទ្ធិ ---------- ២០

៣.២ ការបែងចែកដីធ្លី ដើម្បីគោលដៅសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ---------- ២១

៣.៣ ការដោះស្រាយវិវាទដីធ្លី ---------- ២៣

៣.៤ ការងាររៀបចំដែនដី និងនគរូបនីយកម្ម ---------- ២៥

៣.៥ ការងារសំណង់ ---------- ២៦

**សេចក្តីសន្និដ្ឋាន** ---------- ២៨

**ជំពូកទី ៤ ផែនការយុទ្ធសាស្ត្រឆ្នាំ ២០០៨-២០១០** ---------- ២៩

**ឯកសារយោង** ---------- ៣០

**ឧបសម្ព័ន្ធ** ---------- ៣១

**តារាងម៉ាទ្រីកផែនការយុទ្ធសាស្ត្រ ឆ្នាំ ២០០៨-២០១០** ---------- ៣៥

# បុព្វកថា

រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងនៅក្នុងការកាត់បន្ថយភាពក្រីក្រជូនប្រជាជន ដូចដែលបានចែងច្បាស់នៅក្នុងច្បាប់ជាតិ អន្តរជាតិ **យុទ្ធសាស្ត្រចតុកោណ** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ជាដើម។ នៅក្នុងគោលនយោបាយទាំងនោះបញ្ហាយេនឌ័រ ក៏ត្រូវបានយកចិត្តទុកដាក់ផងដែរ ដោយការចាត់ទុក *"ស្ត្រីគឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិយើង"* នៅក្នុងគ្រប់ដំណើរការនៃ ការអភិវឌ្ឍប្រទេសជាតិ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានបេសកកម្មដឹកនាំ និងគ្រប់គ្រងការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែតំបន់ណា ឬសមត្ថកិច្ចណាដែលរាជរដ្ឋាភិបាលប្រគល់ឱ្យស្ថាប័នមួយផ្សេងទៀត ។ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្រសួងតែងតែគិតគូរដល់បញ្ហាយេនឌ័រនៅក្នុងគ្រប់ដំណើរការការងាររបស់ខ្លួន ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសដល់ស្ត្រីជាមន្ត្រីរាជការរបស់ក្រសួងនៅគ្រប់លំដាប់ថ្នាក់ ដល់គ្រួសារស្ត្រីក្រីក្រ ស្ត្រីជាមេគ្រួសារដែលមានកូនច្រើននៅក្នុងបន្ទុក និងស្ត្រីមេម៉ាយ ស្ត្រីដែលមានស្វាមីជាអ្នកពិការ ជាដើម។

ដើម្បីបញ្ជាក់នូវការប្តេជ្ញាចិត្តក្នុងការលើកកំពស់ស្ថានភាពយេនឌ័ររបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងបានរៀបចំយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ នៅក្នុងផែនការសកម្មភាពរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សំរាប់អនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទី ៣ នៃរដ្ឋសភា និងក្នុងឯកសារបឋម ស្តីពីក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លីរបស់រាជរដ្ឋាភិបាល សំដៅកាត់បន្ថយគម្លាតយេនឌ័រក្នុងវិស័យនេះ លើកកំពស់សិទ្ធិស្ត្រី កែប្រែជីវភាពស្ត្រីក្រីក្រនៅជនបទ និងបង្កើនចំនួនតំណាង ស្ត្រីនៅក្នុងតួនាទីធ្វើសេចក្តីសម្រេច។

ដូចនេះដើម្បីអនុវត្តយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដូចដែលបានលើកឡើងក្នុងឯកសារគោលទាំងពីរខាងលើ ក្រសួងសម្រេចដាក់ចេញនូវផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រពីឆ្នាំ ២០០៨-២០១០ សំរាប់ការតាមដាន ត្រួតពិនិត្យការអនុវត្តទាំងក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងស្ថាប័នផ្ទៃក្នុងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ផ្ទាល់ផង ទាំងក្នុងវិស័យការងារជំនាញដែលស្ថិតក្នុងអាណត្តិបេសកកម្មរបស់ក្រសួងផង ។

តាមរយៈឯកសារនេះ ខ្ញុំសូមអំពាវនាវសុំកិច្ចសហការ និងការគាំទ្រជាស្មារតី ជាបច្ចេកទេស និងហិរញ្ញវត្ថុ ដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក៏ដូចជាក្រុមការងារយេនឌ័ររបស់ក្រសួង ពីសំណាក់ឯកឧត្តម លោកស្រី អស់លោកជាថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ពីអង្គការមិនមែនរដ្ឋាភិបាលនានា និងដៃគូអភិវឌ្ឍន៍ ដើម្បីឱ្យផែនការយុទ្ធសាស្ត្រដែលក្រសួងបានដាក់ចេញនេះសម្រេចបានដោយជោគជ័យ។

ភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**អ៊ឹម ឈុនលឹម**

# សេចក្តីថ្លែងអំណរគុណ

ជាបឋមយើងខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ **ឯកឧត្តម អ៊ឹម ឈុនលឹម** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់ និង **ឯកឧត្តម កើត សារ៉េត** អនុរដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានក្រុមការងារយេនឌ័រ ដែលបានគាំទ្រយ៉ាងខ្លាំងក្លាចំពោះដំណើរការរៀបចំបង្កើតក្រុមការងារយេនឌ័រ និង ការរៀបចំផែនការយុទ្ធសាស្ត្រនេះ។

ឯកសារផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនេះ ជាសមិទ្ធផលដែលបានមកពីការខិតខំប្រឹងប្រែងរបស់សមាជិកក្រុមការងារយេនឌ័រ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលរួមមាន **លោកស្រី អ៊ូ វី** **លោកស្រី យី ផេង** **លោកស្រី ធន់ ភានី លោក សាយេត បូរាមី លោក អេ ប៊ុនធឿន លោក ជុំ ចាន់ថា លោក ហេ សុផាន់ណារ៉ា លោកស្រី ម៉ៅ ឧស្សាហ៍ លោកស្រី តូច ចំនួមណី និងលោកស្រី ពូន ប៉ិន** និងក៏មិនអាចកាត់ផ្តាច់បានអំពីកិច្ចសហការរួមគ្នារវាងក្រុមការងារយេនឌ័រនេះជាមួយនឹងក្រសួងកិច្ចការនារី ក៏ដូចជាក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីដែរ។ លើសពីនេះទៀត សូមថ្លែងអំណរគុណដល់ក្រសួងកិច្ចការនារី ជាពិសេស **លោកស្រី ញាណ សុចិត្រា** ប្រធាននាយកដ្ឋានសមភាពយេនឌ័រ ព្រមទាំង **លោក ឈន ថាវរិទ្ធ** ទីប្រឹក្សារបស់គំរោង *ភាពជាដៃគូដើម្បីសមធម៌យេនឌ័រ* នៅក្នុងការរួមចំណែកធ្វើឱ្យសំរេចបានផ្តល់នូវសមិទ្ធផលនេះ ។

ក្រុមការងារយេនឌ័រសូមថ្លែងនូវអំណរគុណជាអនេកប្បការចំពោះរាល់ការឧបត្ថម្ភគាំទ្រ និងការជួយជ្រោមជ្រែងធ្វើឱ្យឯកសារយុទ្ធសាស្ត្រនេះសំរេចបានជាផ្លែផ្កា សំដៅរួមចំណែកអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការលើកកំពស់ស្ថានភាពយេនឌ័រនៅកម្ពុជា ពិសេសចំពោះកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងស្ថាប័នពាក់ព័ន្ធនានា ដែលបានចូលរួមផ្តល់យោបល់ និងទិន្នន័យសំខាន់ៗ ក្នុងដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រនេះ។

**ក្រុមការងារយេនឌ័រក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

# សេចក្តីផ្តើម

សន្និសីទស្ត្រីពិភពលោកលើកទី៤ នាទីក្រុងប៉េកាំងឆ្នាំ១៩៩៥ បានឯកភាពគ្នាជាឯកច្ឆ័ន្ទក្នុងការផ្តល់ភាពអង់អាចដល់ស្ត្រី ដើម្បីចូលរួមក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេច និងការទទួលបានអំណាចជាគ្រឹះសំរាប់ធ្វើឱ្យរីកចំរើននូវសមភាព អភិវឌ្ឍន៍ និងសន្តិភាព។ ដើម្បីសម្រេចនូវគោលដៅនេះ សន្និសីទទីក្រុងប៉េកាំងបានរៀបចំផែនការសកម្មភាពមួយចំនួន ដែលនាំឱ្យមានការផ្លាស់ប្តូរជាវិជ្ជមានចំពោះស្ថានភាពស្ត្រី។ ផែនការសកម្មភាពនេះបានផ្តោតទៅលើចំណុចទាំង ១២ ដែលពាក់ព័ន្ធនឹងកង្វល់របស់ស្ត្រី ដូចជា នារី និងភាពក្រីក្រ នារី និងការអប់រំ នារី និងសុខភាព អំពើហិង្សាប្រឆាំងនឹងនារី និងជម្លោះប្រដាប់អាវុធ នារី និងការចូលរួមផ្នែកសេដ្ឋកិច្ច នារី និងការធ្វើសេចក្តីសម្រេច យន្តការសំរាប់ភាពឈានទៅមុខរបស់ស្ត្រី សិទ្ធិមនុស្ស និងនារី នារី និងប្រពន្ធ័ផ្សព្វផ្សាយពតិមាន នារី និងបរិស្ថាន ហើយនិងក្មេងស្រី *(របាយការណ៍ជឿនលឿនស្តីពីការអនុវត្តផែនការសកម្មភាពក្រុងប៉េកាំងអំពីបញ្ហាស្ត្រី ឆ្នាំ១៩៩៥-២០០៥)*។

ដោយសារមានការទទួលស្គាល់ជាទូទៅថា ការចូលរួមទាំងស្ត្រី និងបុរសនៅក្នុងសកម្មភាពសេដ្ឋកិច្ច ពិតជាមានសារៈសំខាន់ក្នុងយុទ្ធនាការកាត់បន្ថយភាពក្រីក្រ ។ ហេតុនេះប្រទេសកំពុងអភិវឌ្ឍន៍នានាបានរៀបចំកម្មវិធីអភិវឌ្ឍន៍ ដោយមានគោលដៅរួមសំខាន់ គឺ *កាត់បន្ថយភាពក្រីក្រ* ដែលក្នុងនោះមានបញ្ចូលនូវការលុបបំបាត់វិសមភាពយេនឌ័រក្នុងដំណើរការអភិវឌ្ឍន៍ផងដែរ។

**របាយការណ៍គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ឆ្នាំ ២០០៣** បានផ្តោតការយកចិត្តទុកដាក់ជាពិសេស លើការកាត់បន្ថយឱ្យបានពាក់កណ្តាលនូវសមាមាត្រប្រជាជន ដែលមានប្រាក់ចំណូលទាបជាងខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ បង្កើនអត្រានៃប្រជាជនមានប័ណ្ណកម្មសិទ្ធិដីធ្លីទូទាំងប្រទេស ទាំងទីក្រុង និងជនបទ នៅមុនដំណាច់ឆ្នាំ ២០១៥ ការលុបបំបាត់វិសមភាពយេនឌ័រក្នុងការអប់រំកំរិតមូលដ្ឋាន លុបបំបាត់គំលាតយេនឌ័រសំរាប់ការងារមានប្រាក់បៀវត្សរ៍នៅគ្រប់វិស័យសេដ្ឋកិច្ច លុបបំបាត់គំលាតយេនឌ័រនៅក្នុងស្ថាប័នសាធារណៈ និងកាត់បន្ថយរាល់គ្រប់ទម្រង់នៃអំពើហិង្សាចំពោះស្ត្រី និងកុមារ។

ដើម្បីរួមចំណែកសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា **យុទ្ធសាស្ត្រចតុកោណ** ដើម្បី ***កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព*** នៅក្នុង **ចតុកោណទី ១: ការលើកស្ទួយវិស័យកសិកម្ម *មុំទី២ កំណែទម្រង់ដីធ្លី និងការបោសសំអាតមីន*** បានចែងថា *"ដី និង ទឹក គឺជាធនធានធម្មជាតិសំខាន់ពីរជាមូលដ្ឋាន ដែលអាចយកមកប្រើប្រាស់សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងកាត់បន្ថយភាពក្រីក្រ ជាពិសេសនៅតំបន់ជនបទ។ ដោយបន្តអនុវត្តច្បាប់ភូមិបាល និងគោលនយោបាយដីធ្លី រាជរដ្ឋាភិបាលប្រមូលផ្តុំជាសំខាន់លើវិធានការពង្រឹងប្រព័ន្ធគ្រប់គ្រង បែងចែក និងប្រើប្រាស់ដីធ្លីប្រកបដោយសមធម៌ និងដោយធានាបាននូវប្រសិទ្ធភាពសេដ្ឋកិច្ច តាមរយៈការចុះបញ្ជីដីធ្លី ការបែងចែកដីធ្លី ការធានាសុវត្ថិភាពនៃកម្មសិទ្ធិលើដីធ្លី ការលុបបំបាត់ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដីរដ្ឋដោយខុសច្បាប់ ការដាក់ចេញវិធានការសមស្របដើម្បីទប់ស្កាត់ការប្រមូលដីទុកដោយមិនប្រើប្រាស់ មិនធ្វើផលិតកម្ម ឬអាជីវកម្ម ។ល។"*

**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦ -២០១០** ក៏បានផ្តោតការយកចិត្តទុកដាក់ទៅលើសកម្មភាពអាទិភាពមួយចំនួនដូចជា :

- រៀបចំ និងអនុវត្តគោលនយោបាយទូលំទូលាយស្តីពីដីធ្លី
- កែលម្អ និងអនុវត្តនីតិវិធីនៃការងារចុះបញ្ជីដីធ្លី សម្រាប់រៀបចំការធ្វើប័ណ្ណកម្មសិទ្ធិមានលក្ខណៈជាប្រព័ន្ធ និងមានលក្ខណៈដាច់ដោយដុំ និងផ្តល់ប័ណ្ណកម្មសិទ្ធិសម្រាប់ក្បាលដីយ៉ាងតិចបំផុត ៣២ភាគរយនៃក្បាលដីសរុប (ទីប្រជុំជន និងទីជនបទ) នៅឆ្នាំ ២០១០
- រៀបចំ និងអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ដើម្បីផ្តល់ដីតូចៗ ដោយមានប័ណ្ណកម្មសិទ្ធិសម្រាប់ការតាំងលំនៅដ្ឋាន និងសម្រាប់ការធ្វើកសិកម្មជាលក្ខណៈគ្រួសារ ហើយផ្តល់ដីយ៉ាងតិចបំផុតសម្រាប់ ១០.០០០គ្រួសារក្រីក្រដែលគ្មាន

ដី ដោយឈរលើមូលដ្ឋាននៃការសាកល្បងនៃគម្រោងសម្បទានដីសង្គមកិច្ច ។

- ពង្រឹងគណៈកម្មការសុរិយោដី និងយន្តការផ្សេងទៀត សម្រាប់ដោះស្រាយជម្លោះដីធ្លី ដើម្បីធានាឱ្យមានដំណោះស្រាយជម្លោះប្រកបដោយយុត្តិធម៌ និងទាន់ពេលវេលា។




**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ក្នុងពិធីបើកសិក្ខាសាលាអន្តរជាតិថ្នាក់តំបន់**
**នៅសណ្ឋាគារកាំបូឌីយ៉ាណា អំពីបញ្ហាដីធ្លី**

បញ្ហាយេនឌ័រក៏ត្រូវបានយកចិត្តទុកដាក់ផងដែរនៅក្នុង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០** ក្នុងនោះរួមមាន ការបញ្ជ្រាបយេនឌ័រនៅគ្រប់វិស័យ ជាពិសេសនៅក្នុងវិស័យកសិកម្ម សុខាភិបាល និងអប់រំ ការបង្កើនសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ការកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ ។ល។ និង ។ល។

នៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការសំរបសំរួលរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ កាលពីថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៥ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងកិច្ចការនារីបានស្នើសុំឱ្យក្រសួងទាំងអស់បង្កើតក្រុមការងារយេនឌ័រ និងផែនការសកម្មភាពបញ្ជ្រាបយេនឌ័ររបស់ខ្លួនទាំងក្នុងក្របខ័ណ្ឌស្ថាប័ន ទាំងក្នុងក្របខ័ណ្ឌនៃវិស័យដែលជាអាណត្តិបេសកកម្មការងាររបស់ស្ថាប័ននីមួយៗ ។ ក្នុងហេតុផលនេះហើយ ដែលក្រុមការងារយេនឌ័ររបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានបង្កើតឡើង ហើយក្រោមកិច្ចសហការយ៉ាងជិតស្និទជាមួយគំរោង *ភាពជាដៃគូដើម្បីសមធមិយេនឌ័រ* របស់ក្រសួងកិច្ចការនារី ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនេះត្រូវបានរៀបចំតាក់តែងឡើង ដើម្បីទុកជាឯកសារផ្លូវការក្នុងការអនុវត្តឱ្យបានទូលំទូលាយស្របតាមសមត្ថកិច្ច និងអាណត្តិបេសកកម្មការងារដែលរាជរដ្ឋាភិបាលបានដាក់ចុះ ចំពោះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

# ជំពូកទី ១ ស្ថានភាពយេនឌ័រនៅប្រទេសកម្ពុជា

ស្ថានភាពយេនឌ័រនៅក្នុងប្រទេសកម្ពុជាមានការរីកចំរើនកាន់តែប្រសើរឡើង នៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅ។ របាយការណ៍អភិវឌ្ឍន៍មនុស្សពិភពលោកឆ្នាំ ២០០៥ និង ២០០៦ បានបង្ហាញថា នៅក្នុងចំណោម ១៤០ ប្រទេស សន្ទស្សន៍អភិវឌ្ឍន៍យេនឌ័ររបស់កម្ពុជាស្ថិតក្នុងលំដាប់ទី ៩៧ ដោយថយចុះពីទី ៩៩ ហើយវិធានការណ៍ពង្រឹងភាពអង់អាចយេនឌ័រ ស្ថិតក្នុងលំដាប់ទី ៦៨ ដោយថយចុះពីទី ៧៣។ ទោះជាយ៉ាងណា ប្រទេសកម្ពុជានៅតែមានបញ្ហាប្រឈមមុខផ្សេងទៀតជាច្រើនដែលត្រូវដោះស្រាយ។

## ១.១ ស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចរបស់ស្ត្រី

ការដោះស្រាយអំពីតម្លៃនៅក្នុងសង្គម គឺជាកិច្ចការមួយដ៏លំបាក ដើម្បីសម្រេចអោយបាននូវសមភាពយេនឌ័រនៅក្នុងប្រទេសកម្ពុជា ជាពិសេសសំរាប់ប្រជាជនទាំងឡាយដែលរស់នៅក្នុងតំបន់ជនបទ ដែលប្រពៃណីបុរាណបានចាក់ឬសយ៉ាងជ្រៅនៅក្នុងផ្នត់គំនិតរបស់ពួកគាត់។ នៅក្នុងសង្គមខ្មែរ បុរសត្រូវបានគេទទួលស្គាល់ថា ជាអ្នកមានឥទ្ធិពលជាង បើប្រៀបធៀបទៅនឹងស្ត្រី។ ដូចនេះបុរសតែងតែជាអ្នកធ្វើការសម្រេចចិត្ត ទៅលើកិច្ចការសំខាន់ៗនៅក្នុងគ្រួសារ។

ប៉ុន្តែសព្វថ្ងៃនេះស្ត្រីដែលជាមេគ្រួសារមានចំនួន ២៣.៥ភាគរយ ដែលនេះបានបង្ហាញអោយឃើញអំពីសំពាធមួយយ៉ាងធ្ងន់មកលើពួកគាត់ នៅក្នុងការទទួលរ៉ាប់រងជាអ្នករកប្រាក់ចំណូលសំរាប់ចិញ្ចឹមគ្រួសារ។

លទ្ធផលអង្កេតការប្រើប្រាស់ពេលវេលាឆ្នាំ ២០០៤ បានបង្ហាញថា ស្ត្រីចំណាយពេលច្រើនជាងបុរស ៣ម៉ោង ជារៀងរាល់ថ្ងៃសំរាប់ធ្វើការងារផ្ទះសំបែង។ តាមការពិតស្ត្រីបានរួមចំណែកយ៉ាងច្រើននៅក្នុងវិស័យសេដ្ឋកិច្ច ពីព្រោះប្រសិនបើយើងធ្វើការគណនាជាសាច់ប្រាក់វិញ សំរាប់ការងារផ្ទះសំបែងនេះ ក្នុងទូទាំងប្រទេស ស្ត្រីរកចំណូលបាន ៩ពាន់លានរៀលក្នុងមួយថ្ងៃ បើប្រៀបធៀបទៅនឹងបុរសបានត្រឹមតែជាង ១ពាន់លានរៀលប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី ការងារទាំងនេះមិនត្រូវបានរាប់បញ្ចូលទៅក្នុងសេដ្ឋកិច្ចទេ ដែលនេះអាចអោយយើងនិយាយបានថា ស្ថិតិសេដ្ឋកិច្ចមានភាពលំអៀងនៅក្នុងផ្នែកយេនឌ័រ។

## ១.២ ស្ត្រីនៅក្នុងទីផ្សារពលកម្ម

អត្រាគ្មានការងារធ្វើនៅក្នុងប្រទេសកម្ពុជាសំរាប់ឆ្នាំ ២០០៤ គឺមានកំរិតទាបបំផុតត្រឹមតែ ០,៨ភាគរយ ប៉ុណ្ណោះ។ ប៉ុន្តែបើប្រៀបធៀបទៅនឹងឆ្នាំ ១៩៩៩ អត្រានេះបានកើនឡើងបន្តិច។ មូលហេតុ គឺបណ្តាលមកពីមានការកើនឡើងដ៏គំហុកនៃចំនួនទារកដែលបានកើតនៅក្នុងអំឡុងឆ្នាំ ១៩៨០ ដែលជាហេតុធ្វើអោយទីផ្សារពលកម្មនៅក្នុងប្រទេសកម្ពុជាមានលក្ខណៈពិសេស នៅក្នុងអំឡុងឆ្នាំ ២០០០។ ចាប់ពីឆ្នាំ ១៩៩៩ ដល់ ២០០៤ អត្រាចូលរួមនៅក្នុងកំលាំងពលកម្មសរុបបានកើនឡើងចំនួន ៨.៥ ភាគរយ ពោលគឺស្មើនឹង ៧០.៧ភាគរយ។

ចំនួនយុវជននៅក្នុងកំលាំងពលកម្មដែលស្ថិតក្នុងក្រុមអាយុ ១៥ឆ្នាំ ដល់ ១៩ឆ្នាំ បានកើនឡើងចំនួន ១៩.៨ភាគរយ ពោលគឺស្មើនឹង ៧២.៨ភាគរយ ហើយសំរាប់ក្រុមអាយុ ២០ឆ្នាំ ដល់ ២៤ឆ្នាំវិញ បានកើនឡើងដល់ ៨៣.៦ភាគរយ។ នេះមានន័យថាជារៀងរាល់ឆ្នាំមានយុវជនប្រមាណជា ២៥០.០០០នាក់ បានចូលទៅក្នុងទីផ្សារពលកម្ម។ ដូចនេះប្រទេសកម្ពុជាត្រូវប្រឈមមុខនឹងការបង្កើតការងារអោយបានច្រើន ដើម្បីស្រូបយកកំលាំងពលកម្មទាំងអស់នេះ។

អត្រាចូលរួមរបស់ស្ត្រីនៅក្នុងកំលាំងពលកម្មបានកើនឡើងចំនួន ៤.៨ភាគរយ ដល់ ៧០.៧ភាគរយ នៅឆ្នាំ ២០០៤។ ទោះជាយ៉ាងនេះក្តី នៅក្នុងចំណោមកម្លាំងពលកម្មសកម្មសរុបនៃវិស័យសេដ្ឋកិច្ច ស្ត្រី ៥២ភាគរយ ធ្វើការងារគ្រួសារដែលគ្មាន

ប្រាក់កំរៃ បើប្រៀបធៀបទៅនឹងបុរសចំនួន ៣៥ភាគរយ។

នាពេលកន្លងទៅនេះ មានការថយចុះនូវចំណែករបស់ស្ត្រីនៅក្នុងវិស័យកសិកម្ម និងរុក្ខាប្រមាញ់ពី ៧៨ភាគរយ មកត្រឹមតែ ៥៦.៨ភាគរយប៉ុណ្ណោះនៅឆ្នាំ ២០០៤។ មូលហេតុមួយនៅក្នុងចំណោមមូលហេតុនានា គឺបណ្តាលមកពីការបំលាស់ទីរបស់យុវជនក្មេងៗទៅក្នុងទីប្រជុំជននានា ដើម្បីស្វែងរកការងារធ្វើនៅក្នុងឧស្សាហកម្មកាត់ដេរជាដើម។ នៅក្នុងឆ្នាំ ២០០៤ ចំណែករបស់ស្ត្រីនៅក្នុងវិស័យផលិត បានកើនឡើងជាងពីរដង ដល់ ១២.៥ភាគរយ។

ឧស្សាហកម្មកាត់ដេរមានសារៈសំខាន់ខ្លាំងសំរាប់សេដ្ឋកិច្ចកម្ពុជា ពីព្រោះវាបានស្រូបយកកម្លាំងពលកម្មក្មេងៗជាច្រើនទៅបំរើការនៅក្នុងវិស័យនេះ ជាពិសេសស្ត្រីក្មេងៗដែលមានចំនួនរហូតដល់ ៨៥ភាគរយ នៃកម្លាំងពលកម្មសរុប។ គេបានធ្វើការប៉ាន់ប្រមាណថាវិស័យនេះបានបង្កើតការងារដោយផ្ទាល់ដល់មនុស្សចំនួន ២៧០.០០០នាក់ និងដោយប្រយោលចំនួន ២៤២.០០០នាក់។ ប្រាក់ចំណូលរបស់កម្មករចំនួនពាក់កណ្តាល ត្រូវបានចំណាយទៅលើម្ហូបអាហារ ថ្លៃឈ្នួលផ្ទះ និងការធ្វើដំណើរ ហើយពាក់កណ្តាលទៀតត្រូវបានទុកសំរាប់ផ្គត់ផ្គង់គ្រួសារនៅឯជនបទ និងជាប្រាក់សន្សំ (*វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ខែ មករា ឆ្នាំ ២០០៧*)។

នៅក្នុងវិស័យសាធារណៈវិញ របាយការណ៍រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈចុះថ្ងៃទី ៣១ ខែមិថុនា ឆ្នាំ ២០០៦ បានបង្ហាញថានៅក្នុងចំណោមមន្ត្រីរាជការស៊ីវិលសរុប ១៦៧ ២២០នាក់ ស្ត្រីមានចំនួន ៥១ ០៤៦នាក់ (៣១ភាគរយ)។ ប៉ុន្តែភាគច្រើននៃស្ត្រីទាំងនេះមានតួនាទីតូចតាច ដែលនេះបង្ហាញថាប្រាក់ចំណូលរបស់ពួកគាត់នៅមានកំរិតទាប ហើយពួកគាត់គ្មានឥទ្ធិពលអ្វីទៅលើគោលនយោបាយ និងការសម្រេចចិត្តសំខាន់ៗទៀតផង។ នេះបង្ហាញឱ្យឃើញនូវគម្លាតយេនឌ័រនៅក្នុងវិស័យមុខងារសាធារណៈ ដែលទាមទារឱ្យមានការដោះស្រាយជាបន្ទាន់។

## ១.៣ ស្ត្រីនៅក្នុងវិស័យកសិកម្ម

កសិកម្មនៅតែជាវិស័យមួយដ៏សំខាន់សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ពីព្រោះវាបានផ្តល់ការងារដល់ប្រជាជនរហូតដល់ ៦០ភាគរយនៃប្រជាជនទាំងអស់។ នៅទីជនបទវិញ មានស្ត្រីចំនួន ៦៦.៥ភាគរយ កំពុងធ្វើការងារនៅក្នុងវិស័យនេះ (*អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ ២០០៤*)។

ឃ្លាំមើលសេដ្ឋកិច្ចកម្ពុជា (*វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ខែ មេសា ឆ្នាំ ២០០៧*) បានបង្ហាញថាកំណើននៅក្នុងវិស័យកសិកម្មមានការថយចុះយ៉ាងខ្លាំងពី ១៣.៤ភាគរយនៅឆ្នាំ ២០០៥ មកត្រឹមតែ ៤.៤ភាគរយនៅឆ្នាំ ២០០៦ មូលហេតុដោយសារផលិតកម្មស្រូវទទួលបានផលតិចតួច។ ដរាបណាវិស័យនេះនៅតែពឹងផ្អែកលើធនធានធម្មជាតិ និងល័ក្ខខ័ណ្ឌអាកាសធាតុភូមិសាស្ត្រ នោះវិស័យនេះនឹងមានលក្ខណៈមិនស្ថិតស្ថេរឡើយ។ ដូចនេះវិធានការបន្ទាន់ គឺប្រព័ន្ធស្រោចស្រព និងការគ្រប់គ្រងធនធានធម្មជាតិដ៏មានប្រសិទ្ធភាព ដើម្បីជំរុញការអភិវឌ្ឍនៅក្នុងវិស័យនេះ ដែលនេះអាចផ្តល់ប្រយោជន៍ដោយផ្ទាល់ដល់ស្ត្រីនៅតាមជនបទផងដែរ។

## ១.៤ ស្ត្រី និងការអប់រំ

តាមការបង្ហាញរបស់*ក្រសួងអប់រំយុវជននិងកីឡា ២០០៣-២០០៤* បានបង្ហាញថា អត្រាបោះបង់ចោលការសិក្សារបស់ក្មេងស្រីមានកំរិតខ្ពស់ ជាមធ្យម ២៣ភាគរយ នៅក្នុងកំរិតអនុវិទ្យាល័យ។ មូលហេតុដែលក្មេងស្រីបោះបង់ចោលការសិក្សា រួមមានចម្ងាយពីផ្ទះទៅសាលារៀនឆ្ងាយ គ្មានមធ្យោបាយធ្វើដំណើរ គ្រួសារមានជីវភាពក្រីក្រ ជួយរកប្រាក់ចំណូលសំរាប់គ្រួសារ ជួយរំលែកការងារផ្ទះសំបែង សុវត្ថិភាពក្មេងស្រី និងប្រពៃណីដែលរារាំងមិនឱ្យក្មេងស្រីទៅរស់នៅឆ្ងាយពីគ្រួសារ។

# ជំពូកទី ១ ស្ថានភាពយេនឌ័រនៅប្រទេសកម្ពុជា

ស្ថានភាពយេនឌ័រនៅក្នុងប្រទេសកម្ពុជាមានការរីកចំរើនកាន់តែប្រសើរឡើង នៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅ។ របាយការណ៍អភិវឌ្ឍន៍មនុស្សពិភពលោកឆ្នាំ ២០០៥ និង ២០០៦ បានបង្ហាញថា នៅក្នុងចំណោម ១៤០ ប្រទេស សន្ទស្សន៍អភិវឌ្ឍន៍យេនឌ័ររបស់កម្ពុជាស្ថិតក្នុងលំដាប់ទី ៩៧ ដោយថយចុះពីទី ៩៩ ហើយវិធានការណ៍ពង្រឹងភាពអង់អាចយេនឌ័រ ស្ថិតក្នុងលំដាប់ទី ៦៨ ដោយថយចុះពីទី ៧៣។ ទោះជាយ៉ាងណា ប្រទេសកម្ពុជានៅតែមានបញ្ហាប្រឈមមុខផ្សេងទៀតជាច្រើនដែលត្រូវដោះស្រាយ។

## ១.១ ស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចរបស់ស្ត្រី

ការដោះស្រាយអំពីតម្លៃនៅក្នុងសង្គម គឺជាកិច្ចការមួយដ៏លំបាក ដើម្បីសម្រេចអោយបាននូវសមភាពយេនឌ័រនៅក្នុងប្រទេសកម្ពុជា ជាពិសេសសំរាប់ប្រជាជនទាំងឡាយដែលរស់នៅក្នុងតំបន់ជនបទ ដែលប្រពៃណីបុរាណបានចាក់ឫសយ៉ាងជ្រៅនៅក្នុងផ្នត់គំនិតរបស់ពួកគាត់។ នៅក្នុងសង្គមខ្មែរ បុរសត្រូវបានគេទទួលស្គាល់ថា ជាអ្នកមានឥទ្ធិពលជាង បើប្រៀបធៀបទៅនឹងស្ត្រី។ ដូចនេះបុរសតែងតែជាអ្នកធ្វើការសម្រេចចិត្ត ទៅលើកិច្ចការសំខាន់ៗនៅក្នុងគ្រួសារ។

ប៉ុន្តែសព្វថ្ងៃនេះស្ត្រីដែលជាមេគ្រួសារមានចំនួន ២៣.៥ភាគរយ ដែលនេះបានបង្ហាញអោយឃើញអំពីសំពាធមួយយ៉ាងធ្ងន់មកលើពួកគាត់ នៅក្នុងការទទួលរ៉ាប់រងជាអ្នករកប្រាក់ចំណូលសំរាប់ចិញ្ចឹមគ្រួសារ។

លទ្ធផលអង្កេតការប្រើប្រាស់ពេលវេលាឆ្នាំ ២០០៤ បានបង្ហាញថា ស្ត្រីចំណាយពេលច្រើនជាងបុរស ៣ម៉ោង ជារៀងរាល់ថ្ងៃសំរាប់ធ្វើការងារផ្ទះសំបែង។ តាមការពិតស្ត្រីបានរួមចំណែកយ៉ាងច្រើននៅក្នុងវិស័យសេដ្ឋកិច្ច ពីព្រោះប្រសិនបើយើងធ្វើការគណនាជាសាច់ប្រាក់វិញ សំរាប់ការងារផ្ទះសំបែងនេះ ក្នុងទូទាំងប្រទេស ស្ត្រីរកចំណូលបាន ៩ពាន់លានរៀលក្នុងមួយថ្ងៃ បើប្រៀបធៀបទៅនឹងបុរសបានត្រឹមតែជាង ១ពាន់លានរៀលប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី ការងារទាំងនេះមិនត្រូវបានរាប់បញ្ចូលទៅក្នុងសេដ្ឋកិច្ចទេ ដែលនេះអាចអោយយើងនិយាយបានថា ស្ថិតិសេដ្ឋកិច្ចមានភាពលំអៀងនៅក្នុងផ្នែកយេនឌ័រ។

## ១.២ ស្ត្រីនៅក្នុងទីផ្សារពលកម្ម

អត្រាគ្មានការងារធ្វើនៅក្នុងប្រទេសកម្ពុជាសំរាប់ឆ្នាំ ២០០៤ គឺមានកំរិតទាបបំផុតត្រឹមតែ ០.៨ភាគរយ ប៉ុណ្ណោះ។ ប៉ុន្តែបើប្រៀបធៀបទៅនឹងឆ្នាំ ១៩៩៩ អត្រានេះបានកើនឡើងបន្តិច។ មូលហេតុ គឺបណ្តាលមកពីមានការកើនឡើងដ៏គំហុកនៃចំនួនទារកដែលបានកើតនៅក្នុងអំឡុងឆ្នាំ ១៩៨០ ដែលជាហេតុធ្វើអោយទីផ្សារពលកម្មនៅក្នុងប្រទេសកម្ពុជាមានលក្ខណៈពិសេស នៅក្នុងអំឡុងឆ្នាំ ២០០០។ ចាប់ពីឆ្នាំ ១៩៩៩ ដល់ ២០០៤ អត្រាចូលរួមនៅក្នុងកំលាំងពលកម្មសរុបបានកើនឡើងចំនួន ៨.៥ ភាគរយ ពោលគឺស្មើនឹង ៧០.៧ភាគរយ។

ចំនួនយុវជននៅក្នុងកំលាំងពលកម្មដែលស្ថិតក្នុងក្រុមអាយុ ១៥ឆ្នាំ ដល់ ១៩ឆ្នាំ បានកើនឡើងចំនួន ១៩.៨ភាគរយ ពោលគឺស្មើនឹង ៧២.៨ភាគរយ ហើយសំរាប់ក្រុមអាយុ ២០ឆ្នាំ ដល់ ២៤ឆ្នាំវិញ បានកើនឡើងដល់ ៨៣.៦ភាគរយ។ នេះមានន័យថា ជារៀងរាល់ឆ្នាំមានយុវជនប្រមាណជា ២៥០.០០០នាក់ បានចូលទៅក្នុងទីផ្សារពលកម្ម។ ដូចនេះប្រទេសកម្ពុជាត្រូវប្រឈមមុខនឹងការបង្កើតការងារអោយបានច្រើន ដើម្បីស្រូបយកកំលាំងពលកម្មទាំងអស់នេះ។

អត្រាចូលរួមរបស់ស្ត្រីនៅក្នុងកំលាំងពលកម្មបានកើនឡើងចំនួន ៤.៨ភាគរយ ដល់ ៧០.៧ភាគរយ នៅឆ្នាំ ២០០៤។ ទោះជាយ៉ាងនេះក្តី នៅក្នុងចំណោមកម្លាំងពលកម្មសកម្មសរុបនៃវិស័យសេដ្ឋកិច្ច ស្ត្រី ៥២ភាគរយ ធ្វើការងារគ្រួសារដែលគ្មាន

ប្រាក់កំរៃ បើប្រៀបធៀបទៅនឹងបុរសចំនួន ៣៥ភាគរយ ។

នាពេលកន្លងទៅនេះ មានការថយចុះនូវចំណែករបស់ស្ត្រីនៅក្នុងវិស័យកសិកម្ម និងរុក្ខាប្រមាញ់ពី ៧៨ភាគរយ មកត្រឹមតែ ៥៦.៨ភាគរយប៉ុណ្ណោះនៅឆ្នាំ ២០០៤។ មូលហេតុមួយនៅក្នុងចំណោមមូលហេតុនានា គឺបណ្តាលមកពីការបំលាស់ទីរបស់យុវជនក្មេងៗទៅក្នុងទីប្រជុំជននានា ដើម្បីស្វែងរកការងារធ្វើនៅក្នុងឧស្សាហកម្មកាត់ដេរជាដើម។ នៅក្នុងឆ្នាំ ២០០៤ ចំណែករបស់ស្ត្រីនៅក្នុងវិស័យផលិត បានកើនឡើងជាងពីរដង ដល់ ១២.៥ភាគរយ ។

ឧស្សាហកម្មកាត់ដេរមានសារៈសំខាន់ខ្លាំងសំរាប់សេដ្ឋកិច្ចកម្ពុជា ពីព្រោះវាបានស្រូបយកកម្លាំងពលកម្មក្មេងៗជាច្រើនទៅបំរើការនៅក្នុងវិស័យនេះ ជាពិសេសស្ត្រីក្មេងៗដែលមានចំនួនរហូតដល់ ៨៥ភាគរយ នៃកម្លាំងពលកម្មសរុប។ គេបានធ្វើការប៉ាន់ប្រមាណថាវិស័យនេះបានបង្កើតការងារដោយផ្ទាល់ដល់មនុស្សចំនួន ២៧០.០០០នាក់ និងដោយប្រយោលចំនួន ២៤២.០០០នាក់។ ប្រាក់ចំណូលរបស់កម្មករចំនួនពាក់កណ្តាល ត្រូវបានចំណាយទៅលើម្ហូបអាហារ ថ្លៃឈ្នួលផ្ទះ និងការធ្វើដំណើរ ហើយពាក់កណ្តាលទៀតត្រូវបានទុកសំរាប់ផ្គត់ផ្គង់គ្រួសារនៅឯជនបទ និងជាប្រាក់សន្សំ ( *វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ខែ មករា ឆ្នាំ ២០០៧* ) ។

នៅក្នុងវិស័យសាធារណៈវិញ របាយការណ៍រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈចុះថ្ងៃទី ៣១ ខែមិថុនា ឆ្នាំ ២០០៦ បានបង្ហាញថានៅក្នុងចំណោមមន្ត្រីរាជការស៊ីវិលសរុប ១៦៧ ២២០នាក់ ស្ត្រីមានចំនួន ៥១ ០៤៦នាក់ (៣១ភាគរយ)។ ប៉ុន្តែភាគច្រើននៃស្ត្រីទាំងនេះមានតួនាទីតូចតាច ដែលនេះបង្ហាញថាប្រាក់ចំណូលរបស់ពួកគាត់នៅមានកំរិតទាប ហើយពួកគាត់គ្មានឥទ្ធិពលអ្វីទៅលើគោលនយោបាយ និងការសម្រេចចិត្តសំខាន់ៗទៀតផង។ នេះបង្ហាញឱ្យឃើញនូវគម្លាតយេនឌ័រនៅក្នុងវិស័យមុខងារសាធារណៈ ដែលទាមទារឱ្យមានការដោះស្រាយជាបន្ទាន់។

## ១.៣ ស្ត្រីនៅក្នុងវិស័យកសិកម្ម

កសិកម្មនៅតែជាវិស័យមួយដ៏សំខាន់សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ពីព្រោះវាបានផ្តល់ការងារដល់ប្រជាជនរហូតដល់ ៦០ភាគរយនៃប្រជាជនទាំងអស់។ នៅទីជនបទវិញ មានស្ត្រីចំនួន ៦៦.៥ភាគរយ កំពុងធ្វើការងារនៅក្នុងវិស័យនេះ ( *អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ ២០០៤* ) ។

ឃ្លាំមើលសេដ្ឋកិច្ចកម្ពុជា ( *វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ខែ មេសា ឆ្នាំ ២០០៧* ) បានបង្ហាញថាកំណើននៅក្នុងវិស័យកសិកម្មមានការថយចុះយ៉ាងខ្លាំងពី ១៣.៤ភាគរយនៅឆ្នាំ ២០០៥ មកត្រឹមតែ ៤.៤ភាគរយនៅឆ្នាំ ២០០៦ មូលហេតុដោយសារផលិតកម្មស្រូវទទួលបានផលតិចតួច។ ដរាបណាវិស័យនេះនៅតែពឹងផ្អែកលើធនធានធម្មជាតិ និងល័ក្ខខ័ណ្ឌអាកាសធាតុភូមិសាស្ត្រ នោះវិស័យនេះនឹងមានលក្ខណៈមិនស្ថិតស្ថេរឡើយ។ ដូចនេះវិធានការបន្ទាន់ គឺប្រព័ន្ធស្រោចស្រព និងការគ្រប់គ្រងធនធានធម្មជាតិដ៏មានប្រសិទ្ធភាព ដើម្បីជំរុញការអភិវឌ្ឍនៅក្នុងវិស័យនេះ ដែលនេះអាចផ្តល់ប្រយោជន៍ដោយផ្ទាល់ដល់ស្ត្រីនៅតាមជនបទផងដែរ។

## ១.៤ ស្ត្រី និងការអប់រំ

តាមការបង្ហាញរបស់ *ក្រសួងអប់រំយុវជននិងកីឡា ២០០៣-២០០៤* បានបង្ហាញថា អត្រាបោះបង់ចោលការសិក្សារបស់ក្មេងស្រីមានកំរិតខ្ពស់ ជាមធ្យម ២៣ភាគរយ នៅក្នុងកំរិតអនុវិទ្យាល័យ។ មូលហេតុដែលក្មេងស្រីបោះបង់ចោលការសិក្សា រួមមានចម្ងាយពីផ្ទះទៅសាលារៀនឆ្ងាយ គ្មានមធ្យោបាយធ្វើដំណើរ គ្រួសារមានជីវភាពក្រីក្រ ជួយរកប្រាក់ចំណូលសំរាប់គ្រួសារ ជួយលែកការងារផ្ទះសំបែង សុវត្ថិភាពក្មេងស្រី និងប្រពៃណីដែលរារាំងមិនឱ្យក្មេងស្រីទៅរស់នៅឆ្ងាយពីគ្រួសារ។

## ១.៥ ស្ត្រី និងសុខភាព

យេនឌ័រនៅក្នុងវិស័យសុខភាព គឺជាបញ្ហាប្រឈមមួយដែលរាជរដ្ឋាភិបាលកម្ពុជា និងអង្គការមិនមែនរដ្ឋាភិបាលនានា កំពុងធ្វើការយកចិត្តទុកដាក់ ដោយខិតខំយ៉ាងណា ដើម្បីធ្វើឱ្យប្រសើរឡើងនូវសុខមាលភាពប្រជាជនទូទៅ ជាពិសេសស្ត្រី និងកុមារ ។

បច្ចុប្បន្ននេះអត្រាមរណៈភាពមាតា គឺ ៤៧២នាក់ក្នុងចំណោម ១០០.០០០កំណើតរស់ ។ អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ ២០០០ បានបង្ហាញថា អត្រាមរណៈភាពមាតាគឺ ៤៣៧នាក់ក្នុងចំណោម ១០០.០០០កំណើតរស់ ដែលនេះបញ្ជាក់ឱ្យឃើញថាអត្រាមរណៈភាពមាតាគ្មានការផ្លាស់ប្តូរទេ ចាប់តាំងពីឆ្នាំ ២០០០ ។ ក៏ប៉ុន្តែ មរណៈភាពទារកបានថយចុះគួរឱ្យកត់សំគាល់ពី ៩៥នាក់នៅឆ្នាំ ២០០០ មកត្រឹមតែ ៦៦នាក់នៅឆ្នាំ ២០០៥ ក្នុងចំណោម ១.០០០កំណើតរស់ ។

អត្រាប្រេវ៉ាឡង់មេរោគអេដស៍ នៅក្នុងចំណោមមនុស្សពេញវ័យបានថយចុះគួរឱ្យកត់សំគាល់ ។ ទោះជាយ៉ាងនេះក្តី អត្រានេះនៅមានកំរិតខ្ពស់នៅឡើយ ។ លទ្ធផលអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ ២០០៥ បង្ហាញថា ស្ត្រីពេញវ័យដែលមានអាយុចាប់ពី ១៥-៤៩ឆ្នាំ ចំនួន ០,៦ភាគរយមានផ្ទុកមេរោគអេដស៍ ។ ស្ត្រីមេម៉ាយប្តីស្លាប់ មានអត្រាផ្ទុកមេរោគអេដស៍ ខ្ពស់ជាងគេគឺ ២,៩ភាគរយ ស្ត្រីមេម៉ាយលែងលះឬរស់នៅដាច់ពីគ្នា មាន ១,១ភាគរយ និងស្ត្រីរៀបការ/រស់នៅជាមួយគ្នា មាន ០,៧ភាគរយ ។

## ១.៦ អំពើហិង្សាលើស្ត្រី

តាមរបាយការណ៍បានបង្ហាញឱ្យឃើញមានការកើនឡើងនូវអំពើហិង្សាផ្សេងៗជាច្រើន ដូចជាអំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ (រួមទាំងការរំលោភរបស់ក្រុមបងធំ) អំពើហិង្សាលើស្ត្រីរកស៊ីផ្លូវភេទ ព្រមទាំងការកើនឡើងនូវសេចក្តីរាយការណ៍អំពីស្ត្រី និងកុមារដែលត្រូវបានគេជួញដូរទៅប្រទេសជិតខាង ។ យោងតាមការអង្កេតនាពេលថ្មីៗនេះបានបង្ហាញថា ស្ត្រីចំនួន ២២,៥ភាគរយ នៃស្ត្រីដែលបានចូលរួមក្នុងការសំភាសន៍ បាននិយាយថាខ្លួនបានទទួលអំពើហិង្សាពីប្តីរបស់ខ្លួន ហើយបុរសចំនួន ១២ភាគរយ បានរាយការណ៍ថា ខ្លួនបានទទួលអំពើហិង្សាពីប្រពន្ធ (*ក្រសួងកិច្ចការនារី ឆ្នាំ ២០០៥*) ហើយអំពើហិង្សានេះបានបណ្តាលអោយមានផលប៉ះពាល់អវិជ្ជមានលើគ្រួសារទាំងផ្នែកសេដ្ឋកិច្ច រាងកាយ ផ្លូវចិត្ត សុខភាព និងការសិក្សារបស់កូនក្នុងបន្ទុក ។

រាជរដ្ឋាភិបាលមានការរីកចំរើនក្នុងការបង្កើតឱ្យមានក្របខ័ណ្ឌច្បាប់សំរាប់ដោះស្រាយបញ្ហាទាំងនេះ ដោយបានអនុម័តច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ កាលពីថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៥ ក៏ប៉ុន្តែការអនុវត្តច្បាប់មានកំរិតនៅឡើយ ។

## ១.៧ ស្ត្រីនៅក្នុងនយោបាយ និងការធ្វើសេចក្តីសម្រេច

នៅក្នុងនិតិបញ្ញត្តិ សមាជិកព្រឹទ្ធសភាជាស្ត្រីបានកើនឡើងពី ១៣ភាគរយនៅឆ្នាំ ២០០៣ ដល់ ១៥ភាគរយ នៅឆ្នាំ ២០០៦ ។ ដូចគ្នានេះដែរ នៅក្នុងសភាជាតិវិញ អត្រាសមាជិកសភាជាស្ត្រីបានកើនឡើងជាបន្តបន្ទាប់ ពីនិតិកាលទី ១ រហូតដល់និតិកាលទី ៣ គឺពី ៦ភាគរយ ដល់ ១២ភាគរយ និង ២០ភាគរយ ។

នៅក្នុងនិតិប្រតិបត្តិវិញ ស្ត្រីត្រឹមតែ ៧ភាគរយប៉ុណ្ណោះដែលមានតួនាទីជារដ្ឋមន្ត្រី ៧ភាគរយជារដ្ឋលេខាធិការ និង ១០ភាគរយជាអនុរដ្ឋលេខាធិការ ។

ជាទូទៅ ការចូលរួមរបស់ស្ត្រីនៅក្នុងស្ថាប័ននយោបាយ និងការធ្វើសេចក្តីសម្រេច មានការកើនឡើងគួរឱ្យកត់សំគាល់ ។ ប៉ុន្តែអត្រានេះមានកំរិតទាបនៅឡើយ បើប្រៀបធៀបទៅនឹងប្រទេសផ្សេងៗទៀតនៅក្នុងតំបន់ ។ ស្ត្រីគួរត្រូវបានផ្តល់ឱកាសច្រើនថែមទៀតដើម្បីដើរតួនៅក្នុងតំណែងទាំងនេះ ។

# ជំពូកទី ២ ស្ថានភាពទូទៅនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ២.១ ប្រវត្តិក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់




សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ក្នុងពិធីបើកវេទិកាជាតិនៅវិមានរាជរដ្ឋាភិបាល ស្តីពីដីធ្លី

វិស័យដីធ្លីជាវិស័យមួយដែលមានវេទយិតភាពជាងគេ ដោយសារតែរបបប្រល័យពូជសាសន៍ខ្មែរក្រហមបានបន្សល់នូវមតិកដ៏អាក្រក់មួយនៅក្នុងវិស័យដីធ្លី នោះគឺការលុបបំបាត់ចោល និងធ្វើឱ្យក្រឡាប់ចាក់ទាំងស្រុងនូវស្ថាប័នកម្មសិទ្ធិឯកជន ។ មើលឃើញពីស្ថានភាពនេះ និងដោយសារដីជាធនធានធម្មជាតិមូលដ្ឋានដ៏សំខាន់បំផុតមួយសំរាប់កិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងការកាត់បន្ថយភាពក្រីក្រ ជាពិសេសនៅតំបន់ជនបទ រាជរដ្ឋាភិបាលនីតិកាលទី២ នៃរដ្ឋសភា ក៏បានសម្រេចបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឡើង តាមព្រះរាជក្រម នស/រកម/០៦៩៩ /០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដើម្បីប្រមូលផ្តុំសេវាដែលពាក់ព័ន្ធនឹងការប្រើប្រាស់ដីធ្លីឱ្យស្ថិតនៅក្រោមដំបូលក្រសួងនេះតែមួយ ដោយទទួលយកមន្ត្រីជំនាញបច្ចេកទេស ក៏ដូចជាមន្ត្រីរដ្ឋបាលពីប្រភពខុសៗគ្នា ដូចជាពីក្រសួងមហាផ្ទៃ ពីទីស្តីការគណៈរដ្ឋមន្ត្រី ពីក្រសួងសាធារណការ និងដឹកជញ្ជូន ពីក្រសួងអប់រំ យុវជន និងកីឡា ជាដើម សំដៅកែលំអស្ថានភាពដ៏ធ្ងន់ធ្ងរដែលបានកើតឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ ដែលបណ្តាលមកពីការវិវឌ្ឍដ៏លឿននៃរបបកម្មសិទ្ធិឯកជនលើអចលនទ្រព្យ និងទីផ្សារដី ដូចជាសំណង់អនាធិបតេយ្យនៅទីក្រុង ទីប្រជុំជន បញ្ហាខ្វះខាតផ្នែកច្បាប់ទាក់ទងនឹងកម្មសិទ្ធិលើអចលនទ្រព្យ បញ្ហាពុំទាន់មានយុទ្ធសាស្ត្រនៃការរៀបចំដែនដី និងនគរូបនីយកម្ម ។ល។ ដំណើររៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានកំណត់ដោយអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ដោយមានបេសកកម្មដឹកនាំ និងគ្រប់គ្រងលើការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រ មានអគ្គនាយកដ្ឋានជំនាញចំនួន ០៤ និងនាយកដ្ឋានចំណុះចំនួន ១៦ ។

## ២.២ ប្រវត្តិក្រុមការងារយេនឌ័រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចាត់តាំងជនបង្គោលយេនឌ័រចំនួន ០២រូប ដោយមានភារកិច្ចធ្វើអោយប្រសើរឡើងនូវស្ថានភាពយេនឌ័រនៅក្នុងក្រសួង និងក្នុងការងារដែលទាក់ទងនឹងវិស័យដីធ្លី និងសំណង់។

ដោយការងារបញ្ជ្រាបយេនឌ័រកាន់តែមានការមមាញឹក ក្រុមការងារយេនឌ័ររបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានបង្កើតឡើងនៅថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៥ តាមរយៈសេចក្តីសម្រេចលេខ ២៥ សសរ ដោយមានសមាសភាពសរុបចំនួន ១១រូប ដែលក្នុងនោះស្ត្រីមានចំនួន ៦រូប *(សូមអាននៅក្នុងឧបសម្ព័ន្ធទី ២ សំរាប់ព័ត៌មានលំអិត)*។ ក្រុមការងារនេះមានតួនាទី និងភារកិច្ចដូចតទៅ:

- រៀបចំផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ នៅក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។
- បញ្ជ្រាបសមធមិយេនឌ័រទៅក្នុងគ្របវិស័យការងារជំនាញ ដែលក្រសួងមានបេសកកម្មតាក់តែងឡើង ។
- កសាងផែនការបញ្ជ្រាបយេនឌ័រប្រចាំឆ្នាំ ។
- ស្វែងរកការគាំទ្រថវិកា និងបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ និងអង្គការអន្តរជាតិនានា ដើម្បីអភិវឌ្ឍយុទ្ធសាស្ត្រនៃការងារបញ្ជ្រាបយេនឌ័រនៅក្នុងវិស័យជំនាញ។
- ត្រួតពិនិត្យ និងវាយតំលៃនូវរាល់សកម្មភាពដែលបានអនុវត្តពាក់ព័ន្ធនឹងការងារយេនឌ័រ ទាំងក្នុងក្របខ័ណ្ឌស្ថាប័នក្រសួង ទាំងក្នុងសកម្មភាពអនុវត្តផែនការក្នុងវិស័យ ។

## ២.៣ សមិទ្ធផលសម្រេចបានជាពេលកន្លងមក



**ឯ.ឧ ទេសរដ្ឋមន្ត្រី អ៊ឹម ឈុនលឹម ក្នុងឱកាសបិទសិក្ខាសាលាបូកសរុបការងារឆ្នាំ ២០០៦ របស់ក្រសួង ដនស**

ដើម្បីរួមចំណែកធ្វើឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់រាជរដ្ឋាភិបាល និងធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគ សំរាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងអភិបាលកិច្ចល្អ ក៏ដូចជាការធ្វើឱ្យមានកំណើន ការងារ សមធមិ និងប្រសិទ្ធភាពសេដ្ឋកិច្ច ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ បានបង្ហាញនូវសមិទ្ធផលសម្រេចបានជាច្រើន តាមរយៈរបាយ-ការណ៍ប្រចាំឆ្នាំ ២០០៦ រួមមានការអភិវឌ្ឍន៍ក្របខ័ណ្ឌគោលនយោបាយ និងគតិយុត្ត ការអភិវឌ្ឍស្ថាប័ន ការចុះបញ្ជីដីធ្លី ការដោះស្រាយវិវាទដីធ្លី ការរៀបចំដែនដី ការបែងចែកដីសង្គមកិច្ច និងការគ្រប់គ្រងវិស័យសំណង់ ។

នៅក្នុងឆ្នាំ ២០០៦ ក្រសួង បានរួមជាមួយក្រុមប្រឹក្សាគោលនយោបាយដីធ្លី រៀបចំក្របខ័ណ្ឌគោលនយោបាយ និងគតិយុត្តជាច្រើន ដូចជា ច្បាប់ គោលនយោបាយ អនុក្រឹត្យ សារាចរណែនាំ ប្រកាស សេចក្តីណែនាំរួម ប្រកាសរួម សេចក្តីសម្រេច



**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងលោកជំទាវ ក្នុងពិធីប្រគល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់ប្រជាកសិករ នៅឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ**

និងបទប្បញ្ញត្តិនានា ក្នុងគោលបំណងធ្វើឱ្យរដ្ឋបាលដីធ្លី ការរៀបចំដែនដី នគរូបនីយកម្ម ការបែងចែកដីធ្លី និងការគ្រប់គ្រង សំណង់ ប្រព្រឹត្តទៅដោយភាពរលូន និងអភិបាលកិច្ចល្អ ។

ដោយមន្ត្រីក្នុងក្រសួងភាគច្រើនជាមន្ត្រីជំនាញបច្ចេកទេស ហើយប្រមូលផ្តុំមកពីប្រភពខុស១គ្នា ក្រសួងបានយកចិត្តទុកដាក់ជាអាទិភាព ដល់ការពង្រឹងស្ថាប័ន តាមរយៈការកសាងសមត្ថភាពមន្ត្រីរាជការទៅលើជំនាញផ្សេង១ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចជំនាញរបស់ក្រសួង ។ ជាលទ្ធផលមន្ត្រីចំនួន ១.៤៩៤នាក់ ត្រូវបានបញ្ជូនឱ្យចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលផ្សេង១ទាំងក្នុង និងក្រៅប្រទេស ។

ផ្អែកតាមគោលដៅដែលបានដាក់ចេញនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ក្រសួងនឹងសម្រេចការចុះបញ្ជីដីធ្លីឱ្យបាន ១ លានក្បាលដីនៅឆ្នាំ ២០០៧ និងសម្រេចឱ្យបាន ៦៥ភាគរយនៃក្បាលដីសរុបនៅឆ្នាំ ២០១៥ ។ ជាលទ្ធផល ចាប់តាំងពីផ្តើមអនុវត្តការងារមកដល់ខែ ធ្នូ ឆ្នាំ ២០០៦ ក្រសួងសម្រេចការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ ដោយបានផ្តល់ប័ណ្ណកម្មសិទ្ធិជាស្ថាពរដល់ប្រជាជនចំនួនជាង ៥៦៤.០០០ប័ណ្ណ និងការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំនៅទូទាំងប្រទេស ដោយបានផ្តល់ប័ណ្ណកាន់កាប់ដីភោគៈចំនួន ៥៧៦.០៩៨ ប័ណ្ណផងដែរ ។ សរុបទាំងពីរនីតិវិធី ក្រសួងសម្រេចចេញប័ណ្ណកាន់កាប់ដីធ្លី ដល់ប្រជាជនបានជាង ១.១០០.០០០ ក្បាលដី លើសផែនការដែលបានគ្រោងទុកសំរាប់ឆ្នាំ ២០០៧ ចំនួន ជាង ១សែនក្បាលដី ។

ទាក់ទងនឹងការងារដោះស្រាយវិវាទដីធ្លីវិញ ចាប់ពីដំណើរការរហូតមកដល់ខែធ្នូ ឆ្នាំ ២០០៦ ក្រសួងសម្រេចដោះស្រាយបញ្ចប់បានចំនួន ១.២៤៦ករណី ស្មើនឹងផ្ទៃដីទំហំ ២.៣៩៤ ហិកតា ច្រានចោលចំនួន ៨៧១ករណី និងដកពាក្យចំនួន ៧៩ករណី ។ ចំណុចគួរកត់សំគាល់ តំបន់ដីដែលបានចុះបញ្ជីរួច ពិសេសតំបន់ដែលបានចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ទំនាស់ដីធ្លីនានាដែលកើតមានក្នុងតំបន់នោះត្រូវបានបញ្ចប់ ។

ជាងនេះទៀត ក្រសួងបានរៀបចំជាបន្តបន្ទាប់នូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ស្រុកខណ្ឌ ផែនការប្រើប្រាស់ដីធ្លីនៅតំបន់ទីប្រជុំជន ព្រមទាំងផែនការប្រើប្រាស់ដីធ្លីឃុំសង្កាត់ដោយមានការចូលរួម សេចក្តីព្រាងប្លង់យុទ្ធសាស្ត្រតំរង់ទិសអភិវឌ្ឍន៍ក្រុងភ្នំពេញ ។ ក្រៅពីនេះក្រសួងបានធ្វើការកែសម្រួលបទដ្ឋានប្រើប្រាស់ដីធ្លី នគរូបនីយកម្ម ការងារគ្រប់គ្រងការសាងសង់មួយចំនួន និងកំពុងសហការណ៍ជាមួយគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំប្លង់មេសំរាប់តំបន់អភិវឌ្ឍន៍ ។

លើការងារបែងចែកដីក្នុងគោលដៅសង្គមកិច្ច គិតចាប់ពីពេលផ្ដើមអនុវត្តមកដល់ចុងឆ្នាំ ២០០៦ ក្រសួងបានសហការណ៍ជាមួយអាជ្ញាធរដែនដី ពិសេសគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីធ្លីគ្រប់ខេត្តក្រុង អនុវត្តគោលនយោបាយអភិវឌ្ឍន៍នៅនឹងកន្លែងក្នុងតំបន់ទីក្រុង ទីប្រជុំជនមួយចំនួន ដោយការចែកដីសំរាប់លំនៅឋាន និងការតាំងលំនៅជាថ្មី ដែលជាលទ្ធផលសម្រេចបាន ១៧.០៨៦គ្រួសារ លើផ្ទៃដីសរុបប្រមាណជាង ២.២៦៨ហ.ត។

ដោយឡែកក្នុងក្របខ័ណ្ឌនៃការអនុវត្តអនុក្រឹត្យស្ដីពីសម្បានដីសង្គមកិច្ច ជាកម្មវិធីមួយថ្មីរបស់រាជរដ្ឋាភិបាល ដែលបានសម្រេចផ្ដល់ដីសម្បទានសង្គមកិច្ចឱ្យបាន ១០.០០០គ្រួសារក្រីក្រនៅដំណាច់ឆ្នាំ ២០០៨ ដើម្បីមានមូលដ្ឋានសំរាប់អនុវត្តទូទាំងប្រទេស ក្រសួងបាននិងកំពុងសហការណ៍ជាមួយដៃគូអភិវឌ្ឍន៍ រៀបចំគំរោងសាកល្បងមួយក្នុងស្រុកចំនួនពីរ គឺស្រុកមេមត់ ខេត្តកំពង់ចាម និងស្រុកក្រចេះ ខេត្តក្រចេះ លើផ្ទៃដីសរុបជិត ៥.០០០ហិកតា ដែលបច្ចុប្បន្នកំពុងរៀបចំផែនការអនុវត្តន៍ជាក់ស្ដែងតាមនីតិវិធីដែលមានចែងក្នុងអនុក្រឹត្យ ។

លើសពីនេះ ក្រសួងនៅបានសហការណ៍ជាមួយអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី ដើម្បីធ្វើការបែងចែកដីធ្លីដល់គ្រួសារក្រីក្រដែលគ្មានដីសំរាប់សង់លំនៅឋាន និងធ្វើកសិកម្មជាលក្ខណៈគ្រួសារបាន ២.៣៧១គ្រួសារ លើផ្ទៃដីព្រៃដែលបានដកហូតពីការកាន់កាប់អនាធិបតេយ្យ សរុបចំនួន ៥៧.១០៨ហ.ត។

## ២.៤ បញ្ហាយេនឌ័រនៅក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

### ២.៤.១ ការធ្វើសេចក្ដីសម្រេចរបស់ស្ត្រី



**ឯកឧត្តមទេសរដ្ឋមន្ត្រី អ៊ឹម ឈុនលឹម រដ្ឋមន្ត្រីក្រសួង ដនស បំពាក់មេដាយការងារ ដល់មន្ត្រីមានស្នាដៃ**
**ក្នុងឱកាសទិវានារីអន្តរជាតិ ៨ មិនា**

រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការប្ដេជ្ញាចិត្ត ក្នុងការបង្កើនសមាមាត្រស្ត្រីនៅក្នុងជួរថ្នាក់ដឹកនាំគ្រប់កំរិត ដូចដែលមានចែងនៅក្នុងរបាយការណ៍គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ ប៉ុន្តែតាមរបាយការណ៍របស់ក្រសួងបានបង្ហាញថា តំណាងរបស់ស្ត្រីនៅក្នុងតួនាទី ធ្វើសេចក្ដីសម្រេចនៅគ្រប់លំដាប់ថ្នាក់ ទាំងថ្នាក់កណ្ដាល និងថ្នាក់មូលដ្ឋានមានចំនួនតិចតួច បើប្រៀបធៀបទៅនឹងបុរស។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូបដែលជាបុរស។ តារាងទី ១ ខាងក្រោមបង្ហាញផងដែរ ថាគ្មានតំណាងស្ត្រីនៅក្នុងថ្នាក់រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការឡើយ។

តារាងទី ១: តំណែងថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

| តួនាទី ឬតំណែង | ស្ត្រី | | បុរស | |
|---|---|---|---|---|
| | ចំនួន | % | ចំនួន | % |
| រដ្ឋមន្ត្រី | ០ | ០ | ១ | ១០០ |
| រដ្ឋលេខាធិការ | ០ | ០ | ៥ | ១០០ |
| អនុរដ្ឋលេខាធិការ | ០ | ០ | ៥ | ១០០ |

*ប្រភព: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ ២០០៧*

នៅថ្នាក់ដឹកនាំកណ្តាល គេសង្កេតឃើញថាគ្មានតំណាងស្ត្រីនៅក្នុងតំណែងអគ្គនាយកទេ *(ក្រាហ្វិកទី ១ខាងក្រោម)* ហើយតំណែងអគ្គនាយករង ស្ត្រីមានត្រឹមតែ ២ រូប ប៉ុណ្ណោះ (១០ភាគរយ)។ ស្ត្រីដែលមានតំណែងជាប្រធាននាយកដ្ឋានមានចំនួន ២ រូប (១១ភាគរយ ) អនុប្រធាននាយកដ្ឋានមាន ១ រូប (២ភាគរយ) ប្រធានការិយាល័យមាន ៦ រូប (១២ភាគរយ ) និងអនុប្រធានការិយាល័យមាន ១៨ រូប (១៧ភាគរយ )។ ទាំងនេះបង្ហាញអោយឃើញថា រាល់ការធ្វើសេចក្តីសម្រេចសំខាន់ៗ សម្លេងស្ត្រីចូលរួមយោបល់មានតិចតួចនៅឡើយ។



ទិដ្ឋភាពរួមនៃកិច្ចប្រជុំបំពាក់ឯកសណ្ឋាន និងឋានន្តរសក្តិមន្ត្រីរាជការ និងលោកស្រីបណ្ឌិត អ៊ូ វីឌី ក្នុងសិក្ខាសាលាពីការគ្រប់គ្រងដីរដ្ឋ

ក្រាហ្វិកទី ១: តំណែងរបស់មន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នៅថ្នាក់កណ្តាល (គិតជាភាគរយ)




*ប្រភព: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ ២០០៧*

ដូចគ្នានេះដែរ ក្រាហ្វិកទី ២ ខាងក្រោមបង្ហាញថា នៅថ្នាក់ក្រោមជាតិមានស្ត្រីត្រឹមតែ ១រូបប៉ុណ្ណោះ (៤ភាគរយ) ដែលមានតំណែងជាប្រធានមន្ទីរ ហើយគ្មានស្ត្រីនៅក្នុងតំណែងអនុប្រធានមន្ទីរទេ។ នៅថ្នាក់ការិយាល័យវិញ មានស្ត្រីត្រឹមតែ១រូបប៉ុណ្ណោះ (២ភាគរយ) និង ១១រូប ជាអនុប្រធានការិយាល័យ។ នៅថ្នាក់ការិយាល័យស្រុកវិញ គ្មានតំណាងស្ត្រីជាប្រធានការិយាល័យស្រុកទេ។ ដូច្នេះរាល់ការធ្វើសេចក្តីសម្រេចផ្សេងៗនៅថ្នាក់ក្រោមជាតិ ភាគច្រើនក៏បុរសជាអ្នកសម្រេចដែរ។

**ក្រាហ្វិកទី ២: តំណែងរបស់មន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នៅថ្នាក់ខេត្តក្រុង និងស្រុក (គិតជាភាគរយ)**




*ប្រភព: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ ២០០៧*

មូលហេតុដែលបណ្តាលឱ្យមន្ត្រីជាស្ត្រីភាគច្រើនមិនបានចូលរួមក្នុងការធ្វើសេចក្តីសម្រេច ម៉្យាងមកពីមន្ត្រីជាស្ត្រីដែលក្រសួងបានទទួលពីប្រភពផ្សេងៗ ស្ទើរតែរកអ្នកដែលមានជំនាញឆ្លើយតបនឹងល័ក្ខខ័ណ្ឌការងាររបស់ក្រសួងមិនបាន ពិសេសសំរាប់ថ្នាក់ក្រោមជាតិ គឺស្ទើរតែគ្មាន បើប្រៀបនឹងមន្ត្រីជាបុរស។ ម៉្យាងទៀត នៅអង្គភាពដែលមានស្ត្រី មានសមត្ថភាពសមល្មមនឹងទទួលបានតួនាទីនោះ ស្ត្រីខ្លួនឯងផ្ទាល់ខ្វះសេចក្តីក្លាហានក្នុងការទទួលយកការតែងតាំងសំរាប់ការងារដែលនៅឆ្ងាយពីសង្គមគ្រួសារ និងអាចមកពីកត្តាអត្តនោម័តរបស់ថ្នាក់ដឹកនាំតាមអគ្គនាយកដ្ឋាន និងនាយកដ្ឋាន ក៏ដូចជាមន្ទីរ ដនសស ចំណុះក្រសួងផងដែរ ដែលនៅខ្វះការផ្តល់សារសំខាន់ដល់តួនាទីរបស់ស្ត្រីក្នុងមុខដំណែងដែលមន្ត្រីនារីនោះគួរទទួលបាន។ ឧទាហរណ៍ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងមន្ទីរ ដនសស ក្រុងភ្នំពេញ មានមន្ត្រីជាស្ត្រីដែលមានជំនាញការងារសុរិយោដី និងជំនាញវិស្វកម្ម ព្រមទាំងបទពិសោធន៍ការងារច្រើនឆ្នាំ ដែលពួកគាត់គួរតែត្រូវបានលើកទឹកចិត្ត និងផ្តល់ឱកាសក្នុងការទទួលបានតួនាទីធ្វើសេចក្តីសម្រេចនេះដែរ។



**រូបភាពថ្នាក់ដឹកនាំគ្រប់អង្គភាពក្រោមឱវាទក្រសួង ដនសស ក្នុងសិក្ខាសាលាបូកសរុបការងារឆ្នាំ ២០០៦ របស់ក្រសួង ដនសស**

ដូចនេះគ្រប់ថ្នាក់ គ្រប់ផ្នែកក្រោមឱវាទក្រសួង ត្រូវពិនិត្យចំណុចខ្វះខាតឡើងវិញ ហើយបង្កើនការយកចិត្តទុកដាក់រៀបចំប្រព័ន្ធវាយតម្លៃ និងផែនការបណ្តុះបណ្តាលមន្ត្រីរាជការរបស់ខ្លួន ដោយមិនមានការរើសអើង *និងត្រូវឈរលើគោលការណ៍ដូចដែលឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់* ដែលបានផ្តល់អនុសាសន៍ជារឿយៗក្នុងពិធី

មេទិញអបអរសាទរថ្ងៃបុណ្យទិវាអន្តរជាតិនារី ៨មីនានៅទីស្តីការក្រសួងនោះ *គឺការផ្តល់អាទិភាពពិនិត្យមុខសញ្ញាមន្ត្រីជានារី មុនបង្អស់នៅក្នុងការសម្រេចស្នើតែងតាំង ឬតម្លើងឋានៈដល់មន្ត្រីក្រោមឱវាទ* ដើម្បីឱ្យស្ត្រីមានឱកាសទទួលបាន នូវតួនាទីធ្វើសេចក្តីសម្រេច សំដៅកាត់បន្ថយគម្លាតយេនឌ័រនៅក្នុងក្រសួង។

## ២.៤.២ ការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍធនធានមនុស្ស

ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដែលអាចឆ្លើយតបទៅនឹងការវិវត្តនៃសង្គម និងវិទ្យាសាស្ត្រចាំបាច់ត្រូវមានធនធានមនុស្សដែលមានលក្ខណៈសម្បត្តិជំនាញគ្រប់គ្រាន់។ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏មានចែងផងដែរ ក្នុងចតុកោណទី៤គឺ "*ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស*" ដើម្បីសម្រេចឱ្យបាននូវទិសដៅកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព។



**ឯ.ឧ ទេសរដ្ឋមន្ត្រី អ៊ឹម ឈុនលឹម រដ្ឋមន្ត្រីក្រសួង ដនស ផ្តល់ថវិកាចូលរួមការអបអរសាទរទិវានារីអន្តរជាតិ ៨មិនា ដល់តំណាងស្ត្រីក្នុងក្រសួង ក្នុងឱកាសបិទសិក្ខាសាលាបូកសរុបការងារឆ្នាំ ២០០៦ របស់ក្រសួង**

ទន្ទឹមនេះ,**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០** បានលើកឡើងនូវសកម្មភាពជាអាទិភាពដូចជា "*អភិវឌ្ឍធនធានមនុស្ស និងស្ថាប័ន តាមរយៈការប្រកាសឱ្យប្រើក្របខ័ណ្ឌមួយដើម្បីគ្រប់គ្រងការអភិវឌ្ឍសមត្ថភាព ការគ្រប់គ្រងការអភិវឌ្ឍធនធានមនុស្សប្រកបដោយប្រសិទ្ធភាព ដោយរួមបញ្ចូលទាំងការអនុវត្តផែនការមេសំរាប់ការអភិវឌ្ឍធនធានមនុស្ស និងពង្រឹងតម្លៃនៃការងារបណ្តុះបណ្តាល*"។ នៅក្នុងស្មារតីនេះ ក្រសួងមានផែនការយុទ្ធសាស្ត្ររបស់ខ្លួន គឺ "*លើកកំពស់តុល្យភាពយេនឌ័រ នៃនិស្សិតមហាវិទ្យាល័យ ដោយឱ្យមានការចុះឈ្មោះចូលរៀនដែលមាន ៣០ ភាគរយ យ៉ាងតិចជានិស្សិតនារី និងបន្តលើកស្ទួយសមធម៌យេនឌ័ររបស់មន្ត្រីក្រសួង*"។




**.គណៈអធិបតីនៃសិក្ខាសាសាលាបូកសរុបការងាររបស់ក្រសួងដនស ឆ្នាំ ២០០៦**



**សិក្ខាសាលាផ្សព្វផ្សាយការងារយិនឌ័រក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**



ឯ.ឧ. ទេសរដ្ឋមន្ត្រី អ៊ឹម ឈុនលឹម ក្នុងពិធីចែកប័ណ្ណកម្មសិទ្ធិដីធ្លី ដល់ប្រជាពលរដ្ឋនៅដីដោះមីនរួច ក្នុងខេត្តបន្ទាយមានជ័យ និងលើដីកម្មសិទ្ធិរបស់ប្រជាពលរដ្ឋនៅសង្កាត់ឃ្មួញ ក្នុងក្រុងភ្នំពេញ

ស្របគ្នានេះដែរ នៅក្នុងទិសដៅបន្តរបស់ក្រសួងនាពេលខាងមុខ *(របាយការណ៍បូកសរុប និងវាយតម្លៃសកម្មភាពការងារអនុវត្តយុទ្ធសាស្ត្រចតុកោណ ថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ២០០៦)* ក្រសួងក៏បានផ្តល់អាទិភាពលើការអភិវឌ្ឍ និងពង្រឹងស្ថាប័ន តាមរយៈការបង្កើនសមត្ថភាពមន្ត្រីរាជការ លើជំនាញផ្សេងៗ ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពការងារនៅក្នុងក្រសួង។

ដោយហេតុថាមន្ត្រីជាស្ត្រី ដែលបំរើការនៅក្នុងក្រសួងគិតត្រឹមខែ វិច្ឆិកា ឆ្នាំ ២០០៧ មានចំនួនត្រឹមតែ ៣២២ នាក់ប៉ុណ្ណោះ (១២ភាគរយ) បើប្រៀបធៀបទៅនឹងបុរសចំនួន ២,៤៥៧នាក់ (៨៨ភាគរយ) *(ក្រាហ្វិកទី ៣ ខាងក្រោម)* ក្រសួងតែងតែយកចិត្តទុកដាក់ដល់ការ បង្កើនចំនួនមន្ត្រីរាជការជាស្ត្រីឱ្យបានចូលបំរើការងារក្នុងពេលប្រឡងជ្រើសរើសមន្ត្រីក្របខ័ណ្ឌ និងចូលរៀនក្នុងមហាវិទ្យាល័យរៀបចំដែនដី និងរដ្ឋបាលដីធ្លីប្រចាំឆ្នាំនីមួយៗ។ ប៉ុន្តែការអនុវត្តជាក់ស្តែង វត្តមាននៃការចូលរួមរបស់ស្ត្រីក្នុងការប្រឡង គឺតិចតួច បើប្រៀបនឹងចំនួនបុរសដែលបានដាក់ពាក្យស្នើសុំ។ ជាក់ស្តែងក្នុងឆ្នាំ ២០០៧ ការប្រលងជ្រើសរើសក្របខ័ណ្ឌថ្មីក្នុងចំណោមបេក្ខជនដាក់ពាក្យចំនួន ១៣៦រូប មាននារីតែ ២៣រូប ហើយក្នុងចំណោមអ្នកជាប់ជាស្ថាពរចំនួន ១០៤ រូប មានស្ត្រីចំនួន ១៧ រូប និងការប្រឡងជ្រើសរើសនិស្សិតចូលរៀន ក្នុងចំនួនសិស្សដែលបានដាក់ពាក្យរាប់រយនាក់ មាននារីមិនដល់ ១០ភាគរយផង។

ដូចនេះ ក្រសួងនឹងបន្តសហការជាមួយផ្នែកពាក់ព័ន្ធ ក្នុងការយកចិត្តទុកដាក់ និងផ្តល់ការលើកទឹកចិត្តថែមទៀត ដើម្បីឱ្យស្ត្រីមានឱកាសចូលបំរើការងារបានច្រើន ជាពិសេសនៅរៀងរាល់ពេលប្រលងជ្រើសរើសមន្ត្រីរាជការ និងនិស្សិតអោយចូលក្របខ័ណ្ឌក្រសួង និងសិក្សានៅមហាវិទ្យាល័យដែលក្រសួងបានបង្កើត។

**ក្រាហ្វិកទី ៣៖ តំណាងមន្ត្រីរាជការបុរស-ស្ត្រី នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**




*ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ ២០០៧*

ទាក់ទិននឹងកំរិតអប់រំរបស់មន្ត្រីក្នុងក្រសួងវិញ គេសង្កេតឃើញថាស្ត្រីមានអត្រាតិចជាងបុរសនៅក្នុងគ្រប់កំរិតអប់រំទាំងអស់។ មានស្ត្រីតែម្នាក់ប៉ុណ្ណោះដែលមានកំរិតអប់រំថ្នាក់បណ្ឌិត តិចជាងបុរសចំនួន ៨ដង។ ចំណែកថ្នាក់អនុបណ្ឌិតវិញមានស្ត្រីចំនួនតែ ២រូប (៣ភាគរយ) ហើយថ្នាក់បរិញ្ញាប័ត្រមាន ៤៥រូប (៨ភាគរយ)។ មូលហេតុមួយសំខាន់ គឺក្រសួងនេះជាក្រសួងជំនាញបច្ចេកទេស ដែលជំនាញនេះមិនសូវមានការចាប់អារម្មណ៍ពីសិស្សស្រីប៉ុន្មានទេនាពេលកន្លងមក។ ជាទូទៅនៅថ្នាក់ឧត្តមសិក្សា គេសង្កេតឃើញពុំសូវមាននិស្សិតនារីសិក្សានៅក្នុងមុខជំនាញបច្ចេកទេសដីធ្លី និងសំណង់នេះឡើយ ដែលជាការលំបាកក្នុងការបង្កើនចំនួនស្ត្រីក្នុងអាជីពការងារនេះ ។

**តារាងទី ២: កំរិតការអប់រំរបស់មន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមភេទ**

| កំរិតការអប់រំ | ស្ត្រី | | បុរស | | សរុប | |
|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % |
| បណ្ឌិត | ១ | ១១ | ៨ | ៨៩ | ៩ | ១០០ |
| អនុបណ្ឌិត | ២ | ៣ | ៦១ | ៩៧ | ៦៣ | ១០០ |
| បរិញ្ញាប័ត្រ | ៦២ | ៨ | ៦៣០ | ៩៣ | ៦៩២ | ១០០ |
| បរិញ្ញាប័ត្ររង | ៦១ | ១៥ | ៣៤៥ | ៨៥ | ៤០៦ | ១០០ |
| កម្មករជំនាញ | ៤៩ | ១៥ | ៦០ | ៨៥ | ៦៤៩ | ១០០ |

*ប្រភព: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ ២០០៧*

ដើម្បីប្រឈមនឹងការខ្វះខាត មន្ត្រីជំនាញឯកទេសនៃវិស័យនេះ ក្រសួងបានបង្កើតមហាវិទ្យាល័យមួយ គឺមហាវិទ្យាល័យរដ្ឋបាលដីធ្លី និងរៀបចំដែនដី ដែលក្នុងមួយឆ្នាំត្រូវការនិស្សិតចូលរួមពី ៧០ ទៅ ៨០នាក់ ក្នុងនោះក្រសួងតែងបានផ្តល់អាទិភាពដល់និស្សិតនារី ក្នុងការជ្រើសរើសឱ្យចូលសិក្សា ។ ប៉ុន្តែជាក់ស្តែងចំនួននិស្សិតនារីដែលដាក់ពាក្យចូលរៀន មានចំនួនតិចបំផុត។

ជារួមយើងឃើញថាកំរិតអប់រំរបស់មន្ត្រីជាស្ត្រីមានកំរិតទាបខ្លាំង បើប្រៀបធៀបទៅនឹងបុរស ដែលទាមទារឱ្យមានការគិតគូររកគ្រប់លទ្ធភាពពីគ្រប់ផ្នែកគ្រប់ថ្នាក់ដែលមានការពាក់ព័ន្ធ ដើម្បីលើកទឹកចិត្ត និងផ្តល់ឱកាសដល់ស្ត្រីបានចូលរួមកាន់តែច្រើនក្នុងមុខជំនាញនានាដែលក្រសួងបាន និងកំពុងគ្រោងឡើង។



**ឯ.ឧ កែវ ខេមរ៉ា រដ្ឋលេខាធិការក្រសួង ដនស ក្នុងពិធីបើកវគ្គបណ្តុះបណ្តាលមន្ត្រីជំនាញ អំពីការអាន ការពិនិត្យ និងវិភាគព័ត៌មានលើផែនទីប្រើប្រាស់ដីឃុំ-សង្កាត់**

ឆ្លើយតបទៅនឹងបញ្ហានេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានទំនាក់ទំនងស្វែងរកការគាំទ្រពីខាងក្រៅ ដោយបានបញ្ជូនមន្ត្រីជាស្ត្រីឱ្យចូលរួមជាបន្តបន្ទាប់នៅក្នុងវគ្គបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស។

ប្រភពទិន្នន័យរបស់ក្រសួងអំពីការបណ្តុះបណ្តាលពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០០៦ បានបង្ហាញថា ការចូលរួមរបស់ស្ត្រីនៅក្នុងវគ្គបណ្តុះបណ្តាលក្រៅប្រទេសមានការកើនឡើងពី ៨ ភាគរយ ដល់ ១៧ ភាគរយ និងបានថយចុះមកវិញនៅត្រឹម ២ ភាគរយ ហើយការបណ្តុះបណ្តាលក្នុងប្រទេសបានកើនឡើងពី ២ ភាគរយ ដល់ ៨ ភាគរយ និងបានថយចុះមកវិញនៅត្រឹម៣ ភាគរយ *(សូមមើលក្រាហ្វិកទី ៤ ខាងក្រោម)* ។ មូលហេតុសំខាន់ៗដែលធ្វើឱ្យអត្រាចូលរួមរបស់ស្ត្រីមានការថយចុះ គឺប្រធានបទនៃវគ្គបណ្តុះបណ្តាលខ្លះទាមទារនូវកំរិតជំនាញខ្ពស់ ឬក៏រួមនិងជំនាញភាសាអង់គ្លេស ដែលស្ត្រីក្នុងក្រសួងភាគច្រើនមិនទាន់មានសមត្ថភាពជាមូលដ្ឋានដើម្បីចូលរួមបាន និងម្យ៉ាងទៀតស្ត្រីខ្លួនឯងមានការរារែកក្នុងការចូលរួមផងដែរ ជាពិសេសការលះបង់ពេលវេលាពីគ្រួសារដើម្បីខ្លួនឯង ដើម្បីចូលរួមនៅក្នុងការបណ្តុះបណ្តាលនានា។

**ក្រាហ្វិកទី ៤: អត្រាចូលរួមរបស់មន្ត្រីជាស្ត្រីនៅក្នុងការបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស ២០០៤-២០០៦**




*ប្រភព: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ ២០០៧*

សរុបមក អត្រាចូលរួមរបស់មន្ត្រីជាស្ត្រីនៅក្នុងការបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស នៅក្នុងរយៈពេលបីឆ្នាំកន្លងទៅមានកំរិតទាបនៅឡើយ។ ដូចនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នឹងជំរុញលើកទឹកចិត្តបន្ថែមទៀត ដល់ស្ត្រីឱ្យមានសេចក្តីក្លាហានក្នុងការប្រើឱកាស ផ្តល់ឱកាសសំរាប់ខ្លួនឯងក្នុងការចូលរួម និងទទួលបានការបណ្តុះបណ្តាល និងការអប់រំផ្សេងៗពិសេសចំពោះស្ត្រីដែលមានសមត្ថភាព និងឬមានលក្ខណៈសម្បត្តិអាចបណ្តុះបាន ទៅតាមមុខជំនាញវិជ្ជាជីវៈ ដើម្បីឱ្យពួកគាត់មានសមត្ថភាពកាន់តែប្រសើរឡើងក្នុងការបំពេញការងារ និងអាចមានលទ្ធភាពកាន់តែច្រើនក្នុងការចាប់យកតួនាទីធ្វើសេចក្តីសម្រេចនាពេលខាងមុខ។ ទន្ទឹមនេះ តួនាទីរបស់បុរសនៅក្នុងគ្រួសារ ក៏គួរលើកយកមកពិភាក្សា ដើម្បីធ្វើយ៉ាងណាឱ្យបុរសចូលរួមចែករំលែកការងារនៅក្នុងគ្រួសារ ហើយស្ត្រីអាចមានពេលវេលាគ្រប់គ្រាន់ក្នុងការចូលរួមការបណ្តុះបណ្តាលនានាដោយអារម្មណ៍កក់ក្តៅ។



**ទិដ្ឋភាពនៃការចូលរួមទទួលការបណ្តុះបណ្តាលជំនាញកំព្យូទ័ររបស់មន្ត្រីនារី នៃក្រសួង ដនស នៅមជ្ឈមណ្ឌលកំព្យូទ័រនៃទីស្តីការគណៈរដ្ឋមន្ត្រី**

# ជំពូកទី ៣ ស្ថានភាពយេនឌ័រក្នុងវិស័យដីធ្លី និងសំណង់

ក្នុងឯកសារបថមរបស់រាជរដ្ឋាភិបាល ស្តីពីក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី បានចែងថា " *ដើម្បីឱ្យគោលនយោបាយដីធ្លីឆ្លើយតបនឹងតម្រូវការរបស់ប្រជាជនកម្ពុជាគ្រប់រូប គោលនយោបាយនោះត្រូវឆ្លើយតបទៅនឹងតម្រូវការរបស់ស្ត្រី ។ គោលការណ៍មួយក្នុងចំណោមគោលការណ៍សំខាន់នៃការងារនេះ នោះគឺការចេញប័ណ្ណ និងបន្តធ្វើជាកម្មសិទ្ធិរួមគ្នារវាងប្តី និងប្រពន្ធ ហើយស្ត្រីគួរតែមានតំណាងនៅក្នុងគណៈកម្មាធិការ ឬគណៈកម្មការផ្សេងៗ ដូចជាគណៈកម្មការសុរិយោដី និងក្រុមការងារចូលរួមរៀបចំផែនការប្រើប្រាស់ដីជាដើម* "។ ដោយឡែកក្នុងផែនការរបស់ក្រសួងដែលបានដាក់ចេញសំរាប់អនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្នុងជ្រុងស្តីពីការកសាងសមត្ថភាព និងអភិវឌ្ឍន៍ធនធានមនុស្ស ទាក់ទងនឹងការងារលើកកំពស់សមធម៌យេនឌ័រ ក្រសួងក៏មានការប្តេជ្ញាចិត្តច្បាស់លាស់អំពីការងារនេះ ដែលមានខ្លឹមសារ " *ជំរុញលើកកំពស់តុល្យភាពយេនឌ័រនៅក្នុងក្រុមចុះបញ្ជីដីធ្លី និងមន្ត្រីធ្វើការងារដោះស្រាយវិវាទដី និងធានាសិទ្ធិកាន់កាប់ដីធ្លីរបស់ស្ត្រី* " ។

ខាងក្រោមនេះគឺជាការវិភាគយេនឌ័រ ក្នុងវិស័យដីធ្លី និងសំណង់ ដែលស្ថិតក្នុងអាណត្តិបេសកកម្មការងាររបស់ក្រសួង។

## ៣.១ ការចុះបញ្ជីដីធ្លី និងការផ្តល់ប័ណ្ណកម្មសិទ្ធិ

ការចុះបញ្ជីដីធ្លី និងការផ្តល់ប័ណ្ណកម្មសិទ្ធិ ពិតជាមានសារៈសំខាន់ខ្លាំងណាស់សំរាប់ស្ត្រី។ រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ដល់ស្ត្រី ដោយប្រកាន់ខ្ជាប់នូវគោលការណ៍សំខាន់មួយ គឺការពង្រឹងការអនុវត្តច្បាប់ភូមិបាល ដោយការចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដីធ្លីបានត្រឹមត្រូវ យុត្តិធម៌ ដល់ម្ចាស់ទ្រព្យពិតប្រាកដ ពិសេសការយកចិត្តទុកដាក់ចំពោះទ្រព្យដែលជាកម្មសិទ្ធិរួមគ្នារវាងប្តី និងប្រពន្ធ ។



ឯ.ឧ ឧបនាយករដ្ឋមន្ត្រី សុខ អាន ចុះពិនិត្យ និងចែកប័ណ្ណកម្មសិទ្ធិដីធ្លី ដល់ប្រជាកសិករនៅក្នុងស្រុកគីរីវង់ ខេត្តតាកែវ



ឯ.ឧ ទេសរដ្ឋមន្ត្រី អ៊ឹម ឈុនលឹម ជួបសំណេះសំណាលជាមួយបងប្អូនស្ត្រីជាប្រជាកសិករ ក្នុងតំបន់ចុះបញ្ជីដីធ្លី

ប៉ុន្តែតាមការសង្កេតមុនមានការចុះបញ្ជីដីធ្លី ដោយសារការមិនបានយល់អំពីការកំណត់ប្រភេទទ្រព្យក្នុងគ្រួសារ ដែលមានទ្រព្យផ្ទាល់ខាងប្តី ទ្រព្យផ្ទាល់ខាងប្រពន្ធ និងទ្រព្យរួមប្តីប្រពន្ធ ស្ត្រីមួយចំនួន ពិសេសស្ត្រីនៅជនបទ មិនបានចូលរួមផ្តល់ព័ត៌មានជាក់លាក់អំពីទ្រព្យ ហើយច្រើនឯកភាពឱ្យដាក់ជាទ្រព្យរួមប្តីប្រពន្ធ ទោះជាទ្រព្យនោះខ្លួនផ្ទាល់បានទទួលជាមរតកពីឪពុកម្តាយក៏ដោយ ។ ករណីខ្លះ ទ្រព្យនោះជាទ្រព្យផ្ទាល់ខាងប្រពន្ធ ប៉ុន្តែគាត់យល់ព្រមឱ្យប្តីឈរឈ្មោះជាម្ចាស់ទ្រព្យនោះជំនួសខ្លួនថែមទៀត ដែលជាមូលហេតុធ្វើឱ្យមានបញ្ហាទំនាស់អំពីទ្រព្យរួម និងទ្រព្យដោយឡែកជាហូរហែរ នៅពេលដែលគ្រួសាររបស់គាត់មានបញ្ហាលែងលះ។ មូលហេតុផ្សេងទៀតមានជាអាទិ៍ គំរិតវប្បធម៌ និងការមិនស្វែងយល់ពីច្បាប់ ដែលធ្វើឱ្យស្ត្រីជាភរិយាតែងគិតថា ទោះ

បីជានៅលើប័ណ្ណកម្មសិទ្ធិនោះមានឈ្មោះប្ដីរបស់គាត់តែម្នាក់ឯងក៏ដោយ ក៏ស្ត្រីជាប្រពន្ធតែងគិតថាជាទ្រព្យសម្បត្តិរួមនៅក្នុងគ្រួសារដែរ។

ដើម្បីប្រឈមនឹងបញ្ហានេះ ដោយមានការគាំទ្រពីរាជរដ្ឋាភិបាល ក្រសួងបានផ្ដើមអនុវត្តបច្ចេកវិទ្យាថ្មីនៃការងារចុះបញ្ជីដីធ្លី គឺការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធលើក្បាលដីទូទាំងប្រទេស ដែលបានគ្រោងរយៈពេល ១៥ឆ្នាំ។ ទន្ទឹមនេះ ក្រសួងក៏បាន និងកំពុងអនុវត្តនីតិវិធីចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំផងដែរ។ តាមរយៈគំរោងនេះ ស្ត្រីនៅជនបទមានការចូលរួមច្រើន ពិសេសកំលាំងស្ម័គ្រចិត្តដ៏សំខាន់ដែលក្រសួងបានរៀបចំសំរាប់ធ្វើជាចលករគៀងគរឱ្យប្រជាជន ពិសេសស្ត្រីចូលរួមបានច្រើននៅក្នុងដំណើរការនៃការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ គឺជាកំលាំងស្ត្រីនៅនឹងភូមិនៃទីតាំងអនុវត្តតែម្ដង ជាក់ស្ដែងគ្រាន់តែក្នុងខេត្តកំពង់ចាមមួយ មានជាង ១៣០០នាក់ ។ ជាលទ្ធផល គិតមកត្រឹមដំណាច់ឆ្នាំ ២០០៦ សរុបទាំងពីរនីតិវិធី ក្រសួងបានអនុវត្តការចុះបញ្ជីដី និងចេញប័ណ្ណដីធ្លីជូនប្រជាពលរដ្ឋ បានចំនួន ១.១០០.០០០ក្បាលដី។

ដើម្បីបញ្ជាក់អំពីសមធមិយេនឌ័រក្នុងការទទួលបានសិទ្ធិកម្មសិទ្ធិដីធ្លីនេះ ស្របតាមច្បាប់បញ្ញត្តិការអង្កេតមូលដ្ឋានមួយរបស់គំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី LMAP សហការជាមួយ CDRI ឆ្នាំ ២០០៧ អំពីការងារចុះបញ្ជីដីធ្លីនៅជនបទ និងទីក្រុង ក៏បានផ្ដោតសំខាន់លើការងារនេះដែរ ហើយជាលទ្ធផលបានបង្ហាញថា ក្នុងការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធដែលកំពុងដំណើរការបាន ៨០ភាគរយ នៅតំបន់ជនបទនៃខេត្តក្រុងចំនួន ១១ នោះ បរិមាណម្ចាស់កម្មសិទ្ធិជាស្ត្រីមានច្រើនជាងបុរស ក្នុងនោះទ្រព្យរបស់ស្ត្រីជាប្រពន្ធមាន ២៥ ភាគរយ និងជាទ្រព្យរបស់បុរសជាប្ដីមានតែ ០៥ ភាគរយប៉ុណ្ណោះ ឯទ្រព្យរួមប្ដីប្រពន្ធមានដល់ ៧០ ភាគរយ។



**ទិដ្ឋភាពនៃការសំដែងផ្ទាំងទស្សនីយភាពល្ខោនបាសាក់ អំពីច្បាប់ភូមិបាល ទាក់ទងនឹងសិទ្ធិកម្មសិទ្ធិលើដីធ្លី**

ផ្អែកតាមបទពិសោធន៍ជាវិជ្ជមាននេះ ក្រសួងត្រូវបន្តដំណើរការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធនេះជាបន្តទៀត ដើម្បីធានាបាននូវតម្លាភាព និងសមធមិក្នុងការទទួលបានការគាំពារខាងផ្លូវច្បាប់ អំពីសិទ្ធិកម្មសិទ្ធិលើដីធ្លី ពិសេសចំពោះស្ត្រីដែលជាមុខសញ្ញាងាយរងគ្រោះ។ ការផ្សព្វផ្សាយច្បាប់ភូមិបាលតាមគ្រប់រូបភាព ក៏ជាប្រការមួយចាំបាច់ដែលត្រូវតែអនុវត្តបន្ត ដោយបំផុសលើកទឹកចិត្តស្ត្រីឱ្យចូលរួមស្ដាប់ ដើម្បីពួកគាត់អាចយល់ច្បាស់អំពីសិទ្ធជាកម្មសិទ្ធរបស់ពួកគាត់។

## ៣.២ ការបែងចែកដីធ្លី ដើម្បីគោលដៅសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

ដោយសារភាពក្រីក្រមានការទាក់ទងខ្លាំងទៅនឹងភាពគ្មាន និងឬខ្វះដីធ្លី ដូច្នេះការបែងចែកដីក្នុងគោលដៅសង្គមកិច្ច ជាយុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រធំទាំងបីរបស់រាជរដ្ឋាភិបាល លើការងារកែលំអការគ្រប់គ្រងដីធ្លីនៅកម្ពុជា។ តាមរយៈយុទ្ធសាស្ត្រនេះនឹងនាំទៅរកការកាត់បន្ថយភាពក្រីក្រដោយផ្ទាល់ ដោយការផ្ដល់ឱ្យអ្នកក្រនូវទ្រព្យដែលមានផលិតភាព និងលក្ខ័ខណ្ឌអនុគ្រោះផ្សេងទៀត។ ការបែងចែកដីក្នុងគោលដៅសង្គមកិច្ចនឹងរួមចំណែកដល់កំណើនសេដ្ឋកិច្ច ដោយធ្វើឱ្យដី និងកម្លាំងពលកម្ម

ដែលនៅទំនេរ អាចយកមកប្រើប្រាស់កាន់តែមានប្រសិទ្ធភាព ។ ការបែងចែកដីក៏នឹងរួមចំណែកផងដែរដល់ការងារអភិបាលកិច្ច ដោយកាត់បន្ថយបាននូវវិវាទដីធ្លី និងធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងសង្គមនៅថ្នាក់មូលដ្ឋាន ដែលជាវិភាគទានមួយជួយបន្ថយនូវបន្ទុកផ្នែករដ្ឋបាល និងតុលាការផងដែរ ។



**ទិដ្ឋភាពសិក្ខាសាលាថ្នាក់តំបន់នៅខេត្តបាត់ដំបង អំពីសម្បទានដីសង្គមកិច្ច ក្រោមអធិបតីភាព ឯ.ឧ ទេសរដ្ឋមន្ត្រី អ៊ឹម ឈុនលឹម រដ្ឋមន្ត្រីក្រសួង ដនស និងជាប្រធានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ**

ផ្អែកលើហេតុផលនេះ ក្រសួងកំណត់ទិសដៅដល់ដំណាច់ឆ្នាំ ២០០៨ សម្រេចឱ្យបាននូវការបែងចែកដីធ្លីសំរាប់គ្រួសារក្រីក្រដែលគ្មាន និងឬខ្វះដីពិតប្រាកដ ១០.០០០គ្រួសារ ដោយធ្វើកិច្ចសហការជាមួយអាជ្ញាធរដែនដី ជាពិសេសគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីធ្លីខេត្តក្រុង និងឈរលើគោលការណ៍នៃការបែងចែកដីធ្លីដោយសមធម៌ ដូចដែលបានចែងនៅក្នុងសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាល ស្តីពីគោលនយោបាយដីធ្លី *(ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លីឆ្នាំ ២០០២-ឯកសារបប់ម)* និងសារាចរណែនាំរបស់រាជរដ្ឋាភិបាល លេខ ០៦ សរណន ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ស្តីពីផែនការបែងចែកសម្បទានដីសង្គមកិច្ច ដែលក្នុងនោះបានកំណត់ឱ្យគ្រប់ខេត្តក្រុងខិតខំរកដី សំរាប់ផ្តល់ដល់គ្រួសារក្រីក្រដល់ឆ្នាំ ២០០៨ យ៉ាងតិច៤១៦គ្រួសារក្នុង ០១ខេត្តក្រុង ។

នៅក្នុងដំណាក់ដំបូង ប្រជាពលរដ្ឋត្រូវបានផ្តល់ព័ត៌មានអំពីគំរោងនៃការបែងចែកដីធ្លី តាមរយៈការប្រជុំនៅក្នុងសហគមន៍ ។ ការកំណត់នូវពេលវេលាប្រជុំត្រូវតែគិតគូរផងដែរអំពីភាពទំនេររបស់ស្ត្រីបន្ទាប់ពីប្រកបរបររកស៊ី ឬកិច្ចការគ្រួសារ ដើម្បីផ្តល់លទ្ធភាពឱ្យស្ត្រីចូលរួមស្តាប់ និងពិភាក្សាបានកាន់តែច្រើន ។ ដូចនេះការធានាថាស្ត្រីនឹងទទួលបាននូវព័ត៌មានទាំងនេះ គឺជាប្រការមួយសំខាន់ណាស់ ដើម្បីពួកគាត់អាចចូលរួមនៅគ្រប់ដំណាក់កាលនៃកម្មវិធីបែងចែកដីធ្លីនេះ ។

តាមអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ ២០០៤ បង្ហាញថា ស្ត្រីជាមេគ្រួសារមានចំនួន ២៣.៥ភាគរយ ។ លើសពីនេះ មានគ្រួសារជាច្រើនទៀតដែលស្ត្រីជាអ្នករកប្រាក់ចំណូលសំខាន់សំរាប់គ្រួសារ ។ ដូចនេះការកំណត់នូវលក្ខណៈវិនិច្ឆ័យសំរាប់ជ្រើស-រើសអ្នកទទួលផលពីការបែងចែកដីធ្លី គឺជាប្រការមួយសំខាន់ខ្លាំងណាស់សំរាប់ពួកគាត់ ដែលក្នុងនោះក្រសួងត្រូវគិតគូរមានដូចជា:

- *ស្ត្រីក្រីក្រ មានកូនច្រើន ស្ត្រីមេម៉ាយ ស្ត្រីជាមេគ្រួសារ ត្រូវតែបានផ្តល់អាទិភាព នៅក្នុងការទទួលបានដីសង្គមកិច្ច ។*
- *ស្ត្រីត្រូវមានសិទ្ធិដូចគ្នា នៅក្នុងការកាន់កាប់ និងប្រើប្រាស់ដីធ្លី ។*



**ឯ.ឧ ជា សុផារ៉ា រដ្ឋលេខាធិការក្រសួង ដនស និង ឯ.ឧ ហ៊ុន ណេង អភិបាលខេត្តកំពង់ចាម ជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ ក្នុងតំបន់អនុវត្តគំរោងសម្បទានសង្គមកិច្ច នៅស្រុកមេមត់**

ជាក់ស្តែងក្រសួងបាននិងកំពុងយកចិត្តទុកដាក់ដល់បញ្ហាយេនឌ័រ ដោយបានបញ្ជ្រាបចក្ខុវិស័យនេះទៅក្នុងឯកសារគោល-នយោបាយ និងអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ក៏ដូចជាទៅក្នុងគំរោងអនុវត្តសាកល្បងដែលគាំទ្រដល់កម្មវិធីបែងចែកដីសង្គមកិច្ចនេះ។ ការគាំទ្រដល់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេច និងទទួលបានផលពីគំរោង ក៏ជាអនុកម្មវិធីមួយនៃគំរោងនេះដែរនោះគឺ "គំរោងបែងចែកដីដើម្បីគោលដៅសង្គមកិច្ច និង អភិវឌ្ឍន៍សេដ្ឋកិច្ច-LASED" ដែលបាន និងកំពុងអនុវត្តសាកល្បងនៅក្នុងស្រុកចំនួនពីរ លើផ្ទៃដីជាង ៥០០០ហិកតា គឺនៅស្រុកមេមត់ (៩៥០ហិកតា) និងនៅស្រុកក្រចេះ (៤.៥០០ហិកតា)។

ក្រៅពីគំរោងសាកល្បងកម្មវិធីសម្បទានដីសង្គមកិច្ច តាមគោលការណ៍នៃអនុក្រឹត្យ ស្តីពីសម្បទានដីសង្គមកិច្ច ក្រសួងរួមជាមួយអាជ្ញាធរដែនដីខេត្តក្រុង និងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី អនុវត្តគោលនយោបាយអភិវឌ្ឍន៍នៅនឹងកន្លែងរបស់រាជរដ្ឋាភិបាលក្នុងការផ្តល់ដីធ្លីចែកជូនប្រជាជនក្រីក្រ ក្នុងក្របខ័ណ្ឌនៃការកសាងភូមិថ្មី ការតាំងលំនៅថ្មី ការអនុវត្តផែនការប្រើប្រាស់ដីដោះមីន ការធ្វើនីយ័តកម្មដីកាន់កាប់ខុសច្បាប់ដោយប្រជាជនក្រីក្រជាដើម ដែលសរុបមកដល់ដំណាច់ឆ្នាំ ២០០៦ សម្រេចបានប្រមាណជា ១៧.០០០គ្រួសារ (ក្នុងនោះគ្រួសារដែលមានស្ត្រីជាមេគ្រួសារមានប្រមាណ ២០ភាគរយ) នៅលើផ្ទៃដីសរុបជាង ២.០០០ហិកតា ដែលភាគច្រើនជាប្រភេទដីលំនៅដ្ឋាន ។

សរុបមក ក្រសួងបាន និងកំពុងយកចិត្តទុកដាក់រួចហើយដល់ការលំបាករបស់ស្ត្រីក្រីក្រ ស្ត្រីមេម៉ាយ និងស្ត្រីជាមេគ្រួសារជាដើម នៅក្នុងការបែងចែកដីសម្បទានសង្គមកិច្ចនេះ ទាំងនៅក្នុងគោលនយោបាយ ទាំងនៅក្នុងអនុក្រឹត្យនានា។ ដូចនេះ ក្រសួងត្រូវបន្តធ្វើការតាមដានការអនុវត្តការងារនេះ ដើម្បីធានាស្ត្រីបានចូលរួម និងបានទទួលផលពិតប្រាកដពីការងារនេះ និងដើម្បីរួមចំណែកសម្រេចឱ្យបាននូវគោលដៅសមភាពយេនឌ័រនៅក្នុងវិស័យដីធ្លី។




**សិក្ខាសាលា ស្តីពីការណែនាំបញ្ជ្រាបយេនឌ័រ ក្នុងគំរោងបែងចែកដី ដើម្បីគោលដៅសង្គមកិច្ច និងអភិវឌ្ឍន៍សេដ្ឋកិច្ច**

## ៣.៣ ការដោះស្រាយវិវាទដីធ្លី

វិវាទដីធ្លីជាបញ្ហាធំមួយនៅកម្ពុជា។ កត្តាទាំងឡាយដែលបណ្តាលឱ្យមានវិវាទដីធ្លី មានជាអាទិ៍ ភាពក្រីក្រ ការបាត់បង់ឯកសារសុរិយោដី ការខ្វះការយល់ដឹងរបស់សាធារណៈជន ពិសេសក្នុងជួរស្ត្រី អំពីក្របខ័ណ្ឌច្បាប់ ការរីករាលដាលលទ្ធកម្មលើទ្រព្យរដ្ឋដោយខុសច្បាប់ពីគ្រប់ស្រទាប់ប្រជាជន ការផ្តល់ដីសម្បទានសេដ្ឋកិច្ចដោយមិនបានធ្វើការសិក្សាពីផលប៉ះពាល់សង្គម អតុល្យភាពខាងលទ្ធភាពចូលទៅក្នុងទីផ្សារដី ការប្រព្រឹត្តអំពើពុករលួយក្នុងករណីខ្លះជាដើម។



**ឯកឧត្តមទេសរដ្ឋមន្ត្រី អ៊ឹម ឈុនលឹម រដ្ឋមន្ត្រីក្រសួង ដនស និងជាប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ក្នុងកិច្ចប្រជុំថ្នាក់តំបន់ នៅខេត្តបាត់ដំបង ស្តីពីការពង្រឹងសមត្ថភាពការងាររបស់គណៈកម្មការសុរិយោដីខេត្តក្រុង ស្រុកខណ្ឌ**

ដើម្បីប្រឈមនឹងបញ្ហានេះ រាជរដ្ឋាភិបាលបានបង្កើតយន្តការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការនៅថ្នាក់ជាតិ ថ្នាក់ខេត្តក្រុង និងថ្នាក់ស្រុកខណ្ឌ ( *អនុក្រឹត្យលេខ ៤៧ អ.ន.ក្រ ស្តីពីគណៈកម្មការសុរិយោដី* ដឹកនាំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់) ។ ទាក់ទងនឹងការលើកកំពស់សមធម៌យេនឌ័រក្នុងការអនុវត្តអនុក្រឹត្យនេះ ក្រសួងបានរៀបចំប្រកាសលេខ ១១២ប្រក.ណែនាំការអនុវត្តន៍អនុក្រឹត្យលេខ ៤៧ អនក្រ ដោយបានកំណត់ថា "ប្រធាន គណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌ គប្បីយកចិត្តទុកដាក់បញ្ចូលស្ត្រីជាសមាជិកគណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌ"។ ប៉ុន្តែ ជាក់ស្តែងក្នុងជួរមន្ត្រីគណៈកម្មការសុរិយោដី ដែលបានទទួលការតែងតាំងរួចជាង ៦០០នាក់ មានស្ត្រីតែ ១១រូបប៉ុណ្ណោះ ដោយមូលហេតុវត្តមានមន្ត្រីជាស្ត្រី នៅថ្នាក់ស្រុកខណ្ឌមានចំនួនតិចបំផុត ឬ គ្មានតែម្តង ។

ក្នុងការពិនិត្យ និងដោះស្រាយវិវាទដីធ្លី ក្រសួងបានផ្តោតការយកចិត្តទុកដាក់ចំពោះករណីវិវាទ ដែលមានស្ត្រីជាដើមបណ្តឹង ដែលជាមុខសញ្ញាងាយរងគ្រោះ ដោយបានផ្តល់ឱ្យមានជំនួយការភាគីខាងផ្លូវច្បាប់ ដើម្បីគាំពារពួកគាត់ឱ្យទទួលបានការដោះស្រាយវិវាទប្រកបដោយយុត្តិធម៌ និងមិនលំអៀង។ ជាលទ្ធផលលើករណីពាក្យបណ្តឹងដែលក្រសួង និងគណៈកម្មការសុរិយោដីគ្រប់ថ្នាក់ទទួលបាន គិតត្រឹមឆ្នាំ ២០០៦ បានដោះស្រាយបញ្ចប់ ១.២៤៦ ករណី ស្មើនឹងផ្ទៃដីទំហំ ២.៣៩៤ ហិកតា និងចំនួន ៦.៦៤១ គ្រួសារ ក្នុងនោះបណ្តឹងដែលមានស្ត្រីជាដើមបណ្តឹងមានប្រមាណ ១០ ភាគរយ (ភាគច្រើនជាបណ្តឹងរួម ជាក្រុម ជាពួក ដែលមិនអាចញែកឱ្យបានច្បាស់អំពីចំនួនដើមបណ្តឹង ស្ត្រីប៉ុន្មាន ប្រុសប៉ុន្មាន) ។





**ទិដ្ឋភាពមួយ នៃការងារដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ របស់គណៈកម្មការសុរិយោដី**



**ទិដ្ឋភាពនៃការផ្សព្វផ្សាយច្បាប់ភូមិបាល ទាក់ទងនឹងកម្មសិទ្ធិសមូហភាពរបស់ជនជាតិដើមភាគតិច និងការចូលរួមពិគ្រោះយោបល់របស់បងប្អូនស្ត្រីក្នុងសហគមន៍**

ដូចនេះក្រសួងត្រូវបន្តកិច្ចសហការជាមួយគ្រប់ផ្នែកពាក់ព័ន្ធ ដើម្បីធានាថាស្ត្រីអាចទទួលបាននូវសិទ្ធិការពារខាងផ្លូវច្បាប់នៅពេលជួបប្រទះនូវវិវាទដីធ្លី និងទទួលបាននូវភាពយុត្តិធម៌ ទៅតាមគ្រប់លទ្ធភាពដែលអាចធ្វើបាន ដូចជាការជួយចង្អុលបង្ហាញនូវមេធាវី ដែលពុំយកកំរៃសេវាកម្មជាដើម ។ ការយល់ដឹងអំពីច្បាប់ភូមិបាលនៅក្នុងស្រទាប់ប្រជាជនទូទៅ ក៏ជាយុទ្ធសាស្ត្រមួយរួមចំណែកកាត់បន្ថយនូវបញ្ហាវិវាទដីធ្លីនេះដែរ។ ទន្ទឹមនេះ ក្រសួងត្រូវជំរុញការចូលរួមរបស់ស្ត្រីនៅមូលដ្ឋានឱ្យធ្វើជាជនបង្គោលក្នុងការឃោសនាអប់រំផ្សព្វផ្សាយគៀងគរឱ្យស្ត្រីក្នុងមូលដ្ឋានរបស់ខ្លួនសកម្មចូលរួមបានច្រើនក្នុងការងារស៊ើបអង្កេត ការផ្តល់វត្តមាន និងជាសាក្សីក្នុងពេលបើកសវនការសំរុះសំរួលវិវាទម្តងៗ។



**ប្រជាកសិករម្ចាស់ដី ចូលរួមពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យក្បាលដីរបស់ខ្លួន ក្នុងពេលដែលក្រុមបច្ចេកទេសដីធ្លីចុះសិក្សា និងវាស់វែង (រូបភាពនៅស្រុកជុំគីរី ខេត្តកំពត និងស្រុកព្រៃឈរ ខេត្តកំពង់ចាម)**

## ៣.៤ ការងាររៀបចំដែនដី និងនគរូបនីយកម្ម

ការងាររៀបចំដែនដី ជាគោលនយោបាយធំមួយ ក្នុងចំណោមគោលនយោបាយធំទាំងបីនៃការងារដីធ្លី ដែលបានកំណត់ក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លីរបស់រាជរដ្ឋាភិបាល។ គោលដៅសំខាន់នៃការងារនេះផ្តោតលើការអភិវឌ្ឍផែនការប្រើប្រាស់ដីឱ្យមានប្រសិទ្ធភាព ធានាតុល្យភាពនៃកិច្ចអភិវឌ្ឍរវាងទីក្រុង និងជនបទ និងធានានូវការប្រើប្រាស់ដី និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ដែលនេះក៏ជាផលប៉ះពាល់ដល់សិទ្ធិនៃការចូលរួមរបស់ស្ត្រីក្នុងតំបន់ដែលត្រូវរៀបចំផែនការនេះផងដែរ ដូចដែលក្នុងឯកសារក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លីខាងលើ បានចែងថា "*ដើម្បីឱ្យគោលនយោបាយដីធ្លីឆ្លើយតបនឹងតម្រូវការរបស់ប្រជាជនកម្ពុជាគ្រប់រូប គោលនយោបាយនោះត្រូវឆ្លើយតបទៅនឹងតម្រូវការរបស់ស្ត្រី។ ........ស្ត្រីគួរតែមានតំណាងនៅក្នុងគណៈកម្មាធិការ ឬគណៈកម្មការផ្សេងៗ ដូចជា គណៈកម្មការសុរិយោដី និងក្រុមការងារចូលរួមរៀបចំផែនការប្រើប្រាស់ដីជាដើម*"។



**ពិធីប្រគល់ទទួលផែនទីប្រើប្រាស់ដីឃុំសង្កាត់ ក្រោមអធិបតីភាពឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងឯកឧត្តមទេសរដ្ឋមន្ត្រី អ៊ឹម ឈុនលឹម រដ្ឋមន្ត្រីក្រសួង ដនស នៅក្រសួងមហាផ្ទៃ**

ដោយគិតមកដល់ឆ្នាំ ២០០៦ មានផែនការយុទ្ធសាស្ត្រអភិវឌ្ឍស្រុកខណ្ឌចំនួន១៧ ផែនការប្រើប្រាស់ដីធ្លីសំរាប់ទីប្រជុំជន-ទីក្រុងចំនួន ១៣ និងផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួមចំនួន ២.៤៤ភូមិ នៃឃុំសង្កាត់ ៤៥ ត្រូវបានក្រសួងជំរុញរៀបចំឡើង ដោយមានការពិគ្រោះយោបល់ដោយផ្ទាល់ពីតំណាងប្រជាពលរដ្ឋ ពិសេសពីស្ត្រីនៅមូលដ្ឋានឃុំសង្កាត់ ស្រុកខណ្ឌ និងខេត្តក្រុងដែលជាទីតាំងនៃការសិក្សានេះ ។

ការអភិវឌ្ឍនីតិវិធី និងការកសាងផែនការរៀបចំដែនដី និងនគរូបនីយកម្ម ក៏ដូចជាផែនការកំណត់តំបន់អភិវឌ្ឍន៍នានាត្រូវបានក្រសួងយកចិត្តទុកដាក់អនុវត្តនៅគ្រប់កំរិត ទាំងនៅកំរិតមូលដ្ឋាន ដែលមានតម្រូវការឱ្យមានការចូលរួមផ្តល់មតិយោបល់យ៉ាងទូលំទូលាយពីប្រជាពលរដ្ឋនៅនឹងកន្លែង ដោយមិនមានការរើសអើងស្ត្រី ឬបុរសឡើយ ។ ជាក់ស្តែង តាមការកត់សំគាល់យើងឃើញថាវត្តមានរបស់ស្ត្រីចូលរួមនៅក្នុងកន្លែងខ្លះមានចំនួនច្រើនជាងបុរស ប៉ុន្តែការផ្តល់មតិយោបល់នៅមានកំរិតនៅឡើយដោយសារកង្វះសមត្ថភាពយល់ដឹង និងកង្វះភាពក្លាហាន។

ពិនិត្យជារួមយើងឃើញថាក្រសួងបាន និងកំពុងយកចិត្តទុកដាក់ដល់ការបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងការប្រជុំពិភាក្សានានា ព្រមទាំងផលប៉ះពាល់ទៅលើស្ត្រីនៅតាមតំបន់អភិវឌ្ឍន៍នានា ទាំងនៅក្នុងច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីនានា។ បញ្ហាដែលត្រូវប្រឈមនោះ គឺការអប់រំអំពីក្របខ័ណ្ឌច្បាប់ និងគោលដៅជាយុទ្ធសាស្ត្រ ព្រមទាំងសារសំខាន់នៃការងាររៀបចំដែនដីនេះដល់ប្រជាពលរដ្ឋនៅក្នុងតំបន់អភិវឌ្ឍន៍ ជាពិសេសដល់ស្ត្រី គឺជាប្រការមួយចាំបាច់ដែលក្រសួងត្រូវតែបន្ត ដើម្បីធ្វើឱ្យការចូលរួមរបស់ពួកគាត់នៅក្នុងការពិភាក្សាកាន់តែមានសភាពផុលផុស។

## ៣.៥ ការងារសំណង់

ផ្សារភ្ជាប់នឹងការងាររៀបចំដែនដី និងនគរូបនីយកម្ម ការងារសំណង់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ និងដោយឡែកក្នុងឆ្នាំ២០០៦ មានសន្ទុះរីកចំរើនយ៉ាងខ្លាំងក្លា។ ដោយឡែកក្នុងឆ្នាំ២០០៦ យោងតាមការផ្តល់លិខិតអនុញ្ញាតសាងសង់សំណង់នៅថ្នាក់ជាតិ និងថ្នាក់ខេត្តក្រុងមានតម្លៃសរុបជិត ១.២០០លាន ដុល្លារអាមេរិក។ ចំពោះមុខសន្ទុះរីកចំរើនដ៏ខ្លាំងក្លានេះ ផលប៉ះពាល់ដល់ការចូលរួមរបស់ស្ត្រី ក្នុងវិស័យសំណង់ ក៏ត្រូវបានកត់សំគាល់ផងដែរ ហើយឈរលើមូលដ្ឋាននេះ ក្រសួងបាន និងកំពុងបន្តពង្រឹងតម្លាភាពក្នុងការផ្តល់សេវាពង្រឹងការគ្រប់គ្រងបច្ចេកទេស តាមរយៈការកែសំរួលបទបញ្ញត្តិផ្សេងៗ និងការគ្រប់គ្រងអាជីវកម្មសំណង់។ ក្រៅពីនេះ ក្នុងការរួមចំណែកជំរុញកិច្ចការស្តារ និងអភិវឌ្ឍន៍ប្រទេសជាតិក្នុងវិស័យសំណង់នេះ មានជាអាទិ៍ ការរៀបចំរចនាសម្ព័ន្ធផលិតកម្មឧស្សាហកម្ម រួមទាំងលំនៅឋាន និងសំណង់ផ្សេងទៀតដែលបំរើការរស់នៅរបស់ប្រជា

ពលរដ្ឋ ទាំងស្ត្រី និងបុរស បានប្រកបដោយសុខមាលភាព និងសុវត្ថិភាព ក្រសួងបានចូលរួមក្នុងវេទិការអន្តរជាតិសំខាន់ៗ ដូចជា វេទិកាអាស៊ាន វេទិកាអង្គការពាណិជ្ជកម្មពិភពលោកជាដើម ។




**ឯកឧត្តមទេសរដ្ឋមន្ត្រី អ៊ឹម ឈុនលឹម រដ្ឋមន្ត្រី ក្រសួង ដនស ក្នុងសិក្ខាសាលាផ្សព្វផ្សាយ**
**ពីការងារអង្កេតមូលដ្ឋានលើការចុះបញ្ជីដីធ្លីនៅទីក្រុង និងជនបទ**

ប្រឈមនឹងការវិវឌ្ឍនៃវិស័យនេះ សកម្មភាពសាងសង់មានការរីកចំរើនពីមួយឆ្នាំ ទៅមួយឆ្នាំ ជាពិសេសការសាងសង់សំណង់ធំៗដូចជា សំណង់ អគារស្នាក់នៅរួម និងទីក្រុងរណប សំណង់បុរីលំនៅឋាន ភូមិគ្រឹះ រោងចក្រ អគារលក់ទំនិញដែលមានលក្ខណៈជាផ្សារទំនើប មជ្ឈមណ្ឌលពាណិជ្ជកម្ម ធនាគារ សណ្ឋាគារ មន្ទីរពេទ្យ គ្រឹះស្ថានសិក្សា ឃ្លាំង ស្ថានីយប្រេងឥន្ធនៈ។ល។ ដែលគំរោងទាំងអស់នេះតែងតែមានការផ្តល់មតិផ្នែកជំនាញពីគ្រប់ថ្នាក់ ដែលក្នុងនោះមានវិស្វករ-ស្ថាបត្យករជានារីចូលរួមផងដែរ។ ករណីដែលសំណង់នោះជាទ្រព្យរួមរបស់ប្តី និងប្រពន្ធ ក្រសួងតែងតម្រូវឱ្យមានការផ្តិតមេដៃទាំងពីរភាគីលើពាក្យស្នើសុំក៏ដូចជាលើកិច្ចសន្យានានា។ ប៉ុន្តែការអនុវត្តជាក់ស្តែង អាចនៅមានការធ្វេសប្រហែសទាំងខាងមន្ត្រីជំនាញរបស់ក្រសួង ទាំងខាងភាគីម្ចាស់ទ្រព្យដែលស្នើសុំសាងសង់ ដែលស្ត្រីច្រើនតែផ្តល់សិទ្ធិឱ្យបុរសជាស្វាមី ជាកូន ជាប្អូន ក្នុងការចុះហត្ថលេខាជំនួសនៅលើប្លង់ ឬកិច្ចសន្យាសាងសង់។

ចំណុចខ្វះខាតនេះទាមទារឱ្យមានការកែលំអរ និងអប់រំ ដើម្បីបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេចកាន់តែប្រសើរថែមទៀត ។



**ជំនួបពិភាក្សាការងាររវាងរដ្ឋមន្ត្រីក្រសួង ដនស និងរដ្ឋមន្ត្រីក្រសួងសំណង់វៀតណាម**
**អំពីទំនាក់ទំនងសហប្រតិបត្តិការនៃក្រសួងទាំងពីរ**

# សេចក្តីសន្និដ្ឋាន

ជារួមការងារគ្រប់ផ្នែកគ្រប់ថ្នាក់ ដែលស្ថិតក្នុងសមត្ថកិច្ចទទួលខុសត្រូវរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ មានទំនាក់ទំនងផ្សារភ្ជាប់ជាមួយនឹងបញ្ហាយេនឌ័រ ទាំងក្នុងទិដ្ឋភាពស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស ទាំងក្នុងទិដ្ឋភាពនៃវិស័យជំនាញបច្ចេកទេសដែលជាអាណត្តិបេសកកម្មការងាររបស់ក្រសួងផ្ទាល់។ ចំណុចវិជ្ជមានដែលត្រូវបានកត់សំគាល់អំពីអំណះអំណាងខាងលើនេះ គឺបញ្ហាយេនឌ័រត្រូវបានថ្នាក់ដឹកនាំក្រសួង ទាំងនៅថ្នាក់កណ្តាល និងថ្នាក់ក្រោមជាតិយកចិត្តទុកដាក់បញ្ជ្រាបនៅក្នុងរាល់គោលនយោបាយ និងគតិយុត្ត ក៏ដូចជាគំរោងសកម្មភាពនានាដែលក្រសួងបានតាក់តែង និងដាក់ចេញ។ ចំណុចអវិជ្ជមាន គឺនៅសល់តែការប្រតិបត្តិបណ្តាគោលនយោបាយ និងគតិយុត្តិនេះជាក់ស្តែងតែប៉ុណ្ណោះ ដែលក្នុងនោះមុនបង្អស់គឺការយកចិត្តទុកដាក់អប់រំ បណ្តុះបណ្តាល គៀងគរការចូលរួមឱ្យបានសកម្មពីគ្រប់ផ្នែកជំនាញក្នុងការទាក់ទាញ និងលើកកំពស់ការចូលរួមរបស់មន្ត្រី និងប្រជាពលរដ្ឋជានារីឱ្យបានច្រើន ពិសេសការភ្ញាក់រឭកដើម្បីចូលរួមរបស់នារីខ្លួនឯង គឺជាកត្តាគន្លឹះ។

ដើម្បីប្រឈមនឹងភាពអវិជ្ជមានដែលនៅសេសសល់ ក្រសួងមានការប្តេជ្ញាបន្តខិតខំថែមទៀតក្នុងការអភិវឌ្ឍនូវភាពជាវិជ្ជមាន និងកាត់បន្ថយជាបន្តបន្ទាប់នូវភាពអវិជ្ជមាន សំដៅរួមចំណែកធ្វើឱ្យសំរេចនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា ក្នុងការលុបបំបាត់នូវគម្លាតយេនឌ័រចេញពីផ្នត់គំនិតនៃសង្គមកម្ពុជា ដោយចាត់ទុកការអប់រំផ្សព្វផ្សាយ លើកទឹកចិត្ត និងការបង្កឱកាសឱ្យមន្ត្រី និងប្រជាពលរដ្ឋជានារី មានវត្តមានដោយស្មើភាពនៅក្នុងការពង្រឹងភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំ ការអភិវឌ្ឍធនធានមនុស្ស និងការពង្រឹងអភិបាលកិច្ចល្អ ដែលជាកត្តាគន្លឹះ ។

ទន្ទឹមនេះ ដើម្បីសំរេចបាននូវការប្តេជ្ញាចិត្តខាងលើ ក៏ទាមទារផងដែរនូវការគាំទ្រជាស្មារតី សំភារៈ និងហិរញ្ញវត្ថុពីគ្រប់ដៃគូពាក់ព័ន្ធ ដល់ក្រុមការងារយេនឌ័ររបស់ក្រសួង ឱ្យមានសមត្ថភាព មានឱកាស និងលទ្ធភាពគ្រប់គ្រាន់ នៅក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រដែលបានដាក់ចេញឱ្យទទួលបានជោគជ័យ ។

# ជំពូកទី ៤ ផែនការយុទ្ធសាស្ត្រឆ្នាំ ២០០៨-២០១០

ខាងក្រោមនេះគឺជាគោលដៅនៃការបញ្ជ្រាបយេនឌ័រ *(សូមអានតារាងពិស្តារនៅក្នុងឧបសម្ព័ន្ធទី ៣)* នៅក្នុងវិស័យដីធ្លី នគរូបនីយកម្ម និងសំណង់ :

១. ការកើនឡើងនូវការយល់ដឹងអំពីទស្សនៈយេនឌ័រ និងការវិភាគយេនឌ័រដល់បណ្តាញការងារយេនឌ័រ និងមន្ត្រីក្រសួង នៅគ្រប់ខេត្ត-ក្រុង។

២. ចំនួនស្ត្រីនៅក្នុងតួនាទីថ្នាក់ដឹកនាំមានការកើនឡើង។

៣. ការចុះឈ្មោះ និងផ្តល់ប័ណ្ណកម្មសិទ្ធិរួមគ្នារវាងប្តី និងប្រពន្ធ ត្រូវបានបន្ត និងបង្កើនការយកចិត្តទុកដាក់។

៤. ស្ត្រីជាមេគ្រួសារក្រីក្រ ស្ត្រីមេម៉ាយ និងស្ត្រីដែលជាអ្នករកចំណូលចិញ្ចឹមគ្រួសារ ត្រូវបានផ្តល់អាទិភាពក្នុងការទទួលបានដីសម្បទានសង្គមកិច្ច។

៥. ស្ត្រីត្រូវបានធានានូវការទទួលបានសិទ្ធិគាំទ្រខាងផ្លូវច្បាប់នៅពេលមានបញ្ហាវិវាទដីធ្លី។

៦. ការចូលរួមរបស់ស្ត្រីក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានការកើនឡើង។

# ឯកសារយោង


***របាយការណ៍គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ២០០៣*** ក្រសួងផែនការ ភ្នំពេញ ឧបត្ថម្ភដោយ មូលនិធិ UNDP និង Sida ។

***របាយការណ៍ជឿនលឿនស្តីពីការអនុវត្តផែនការសកម្មភាពក្រុងប៉េកាំងអំពីបញ្ហាស្ត្រី ឆ្នាំ ១៩៩៥-២០០៥*** ក្រសួងកិច្ចការនារី ខែធ្នូ ឆ្នាំ ២០០៤។

***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០*** រាជរដ្ឋាភិបាលកម្ពុជា ខែធ្នូ ឆ្នាំ២០០៥។

***យុទ្ធសាស្ត្រចតុកោណ*** រាជរដ្ឋាភិបាលកម្ពុជា ខែកក្កដា ឆ្នាំ ២០០៤។

***អង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ ២០០០-២០០៥*** វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងវិទ្យាស្ថានជាតិស្ថិតិ ភ្នំពេញ ខែធ្នូ ឆ្នាំ ២០០៦ ឧបត្ថម្ភដោយ UNFPA, UNICEF, USAID, ADB, DFID, និង CDC ។

***អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ ២០០៤*** វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ភ្នំពេញ ខែកញ្ញា ឆ្នាំ ២០០៥។

***ការពិនិត្យលើការចំណាយសាធារណៈរបស់ធនាគារពិភពលោក*** *ឆ្នាំ ២០០២* ។

***ច្បាប់ភូមិបាល*** ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១។

***របាយការណ៍បូកសរុប និង វាយតម្លៃសកម្មភាពការងារអនុវត្តយុទ្ធសាស្ត្រចតុកោណ*** ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៦។

***ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី-ឯកសារបឋម*** ទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០២។

***Human Development Report 2005-2006***, UNDP.

*UNDP Cambodia Gender Mainstreaming Initiative 2007,* UNDP Phnom Penh (2007).

***Cambodia's Garment Industry Post-ATC:*** Human Development Impact Assessment, Economic Institute of Cambodia, UNDP-RCC, January, 2007.

***Cambodia Economic Watch,*** Economic Institute of Cambodia, 2007.

***The House of Representative,*** 2007.

***Report of State Secretariat of Civil Service***, 31 June 2006.

***Violence Against Women: a baseline survey***, Ministry of Women's Affairs, Phnom Penh 2005.

***Gender Terminology,*** Ministry of Women's Affairs and JICA, Phnom Penh 2006.

***Guidelines on Gender Mainstreaming in LASED Project,*** Kyoko Kusakabe and SoRothavy, Ministry of Land Management Urban Planning, and Construction, June 2007.

***Registration of Land and Women's Land Rights on Java,*** Jennifer Brown and Firliana Purwanti, Rural Development Institute, Seatle, Washington 98105 USA, August 2002.

***Gender and Access to Land,*** FAO Land Tenure Studies, FAO 2002.

***Are We Not Peasants Too?*** *Land Rights and Women's Claims in India,* Bina Agrawal, Th Population Council, Inc. One Dag Hammarskjold Plaza, New York 10017 USA, 2002.

***Mainstreaming Gender Issues in Land Administration Awareness, Attention and Actio*** Karin HALDRUP, EASE International, DK-1453 Copenhagen K, Denmark, 2002.

***Gender and Equity Isues in Land Tendure Arrangements in China,*** Linxiu Zhang a Chengfang Liu, Center for Chinese Agriculture Policy, IGSNRR-CAS, May 2002.

***Report: Land Reform in Ukraine and Equal Opportunities for Women and Men in L[illegible]d Ownership,*** Ukrainian-Swedish Project, Sida, Swedesurvey, 2002.

# ឧបសម្ព័ន្ធ

១. គោលការណ៍ណែនាំសំរាប់ក្រុមការងារយេនឌ័រនៅតាមក្រសួងពាក់ព័ន្ធនានា

២. សមាជិកភាពក្រុមការងារយេនឌ័រក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

៣. ផែនការយុទ្ធសាស្ត្រ ឆ្នាំ ២០០៨-២០១០

៤. បញ្ជីត្រួតពិនិត្យសំរាប់ការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធី ឬ គំរោង

៥. វាក្យសព្ទបច្ចេកទេសយេនឌ័រ

## ឧបសម្ព័ន្ធ ១: គោលការណ៍ណែនាំសំរាប់ក្រុមការងារយេនឌ័រនៅតាមក្រសួងពាក់ព័ន្ធនានា

### ១. សមាជិកភាពរបស់ក្រុម

ប្រធាន : រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ (បើអាចគួរជាសមាជិករបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី)

អនុប្រធាន : អគ្គនាយក ឬអគ្គនាយករង

សមាជិក : ១រូប ពីគ្រប់នាយកដ្ឋាន

សមាជិកក្នុងក្រុមគួរមាន:

- តុល្យភាពរវាងបុរស និងស្ត្រី ។
- ចំណេះដឹង សមត្ថភាព និងជំនាញ នៅក្នុងក្រសួងរបស់គេ ជាពិសេស ពាក់ព័ន្ធនឹងស្ត្រី ។
- សុឆន្ទៈក្នុងការបង្កើនសមធម៌យេនឌ័រទៅក្នុងគោលនយោបាយ កម្មវិធី និងការគ្រប់គ្រង ។
- យល់ដឹងជាមូលដ្ឋានពីគោលគំនិតនៃការបញ្ជ្រាបយេនឌ័រ ។
- នៅក្នុងតួនាទីដែលអាចមានឥទ្ធិពល និងអាចស្វែងរកការគាំទ្រសំរាប់ការបញ្ជ្រាបយេនឌ័រ ។
- ជំនាញក្នុងការរៀបចំកម្មវិធី និងផែនការ ។
- សមត្ថភាពជាអ្នកស្វែងរកការគាំទ្រមតិសំរាប់បញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ កម្មវិធី និងការអនុវត្តន៍ជាក់ស្តែង ។
- បញ្ចូលជនបង្គោលយេនឌ័រ និងមន្ត្រីដែលធ្វើការងារបញ្ជ្រាបយេនឌ័រក្នុងពេលបច្ចុប្បន្ននៅតាមក្រសួងនីមួយៗ ។

***កំណត់ចំណាំ:*** រាល់សមាជិកនីមួយៗនៅក្នុងក្រុម មិនចាំបាច់មានគ្រប់លក្ខណៈវិនិច្ឆ័យដូចបានរៀបរាប់ខាងលើនេះទេ ប៉ុន្តែនៅក្នុងក្រុមទាំងមូលត្រូវតែមានលក្ខណៈវិនិច្ឆ័យទាំងអស់នេះ ។

### ២. ភារកិច្ចសំខាន់ៗ

- ធ្វើការពិនិត្យទៅលើកម្មវិធី និងសកម្មភាពតាមវិស័យនីមួយៗ វិភាគរកផលប៉ះពាល់ និងឥទ្ធិពលរបស់សកម្មភាពទាំងអស់នេះទៅលើបុរស-ស្ត្រី ។
- ពិនិត្យ និងផ្តល់អនុសាសន៍ពាក់ព័ន្ធនឹងបញ្ហាយេនឌ័រលើកម្មវិធី និងគំរោងថ្មីៗ ក្នុងក្រសួងរបស់គេ ។
- ពិនិត្យលើស្ថានភាពបច្ចុប្បន្នរបស់ស្ត្រីនៅក្នុងក្រសួង និងស្ថាប័នរបស់ពួកគេ និងផ្តល់អនុសាសន៍សំរាប់លើកកំពស់ស្ត្រីទៅក្នុងតួនាទីធ្វើសេចក្តីសម្រេច ។
- រៀបចំសេចក្តីព្រាងគោលនយោបាយ និងផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ សំរាប់សាមីក្រសួង ។
- បញ្ជូនតំណាងចូលរួមក្នុងក្រុមការងារតាមវិស័យនីមួយៗ ដើម្បីស្វែងរកការគាំទ្រមតិលើបញ្ហាយេនឌ័រ ព្រមទាំងជាសមាជិកក្រុមការងារបច្ចេកទេសយេនឌ័រ ។
- ចូលរួមក្នុងការធ្វើផែនការ និងកម្មវិធីនៅក្នុងក្រសួង ដើម្បីធានាថាផែនការនិងកម្មវិធីទាំងនោះមានការឆ្លើយតបនឹងយេនឌ័រ ។
- បង្កើនចំណេះដឹងពីទស្សនៈ និងគោលគំនិតយេនឌ័រ និងស្វែងរកការគាំទ្រមតិ ដើម្បីឱ្យកម្មវិធី និងសកម្មភាពនានានៅក្នុងក្រសួងមានភាពឆ្លើយតបនឹងយេនឌ័រ ។
- គៀងគរធនធានជាតិសំរាប់ការបញ្ជ្រាបយេនឌ័រ ។

***កំណត់ចំណាំ:*** រាល់សមាជិកនីមួយៗនៅក្នុងក្រុម មិនចាំបាច់មានគ្រប់លក្ខណៈវិនិច្ឆ័យដូចបានរៀបរាប់ខាងលើនេះទេ ប៉ុន្តែនៅក្នុងក្រុមទាំងមូលត្រូវតែមានលក្ខណៈវិនិច្ឆ័យទាំងអស់នេះ ។

# ឧបសម្ព័ន្ធ ២: សមាជិកភាពក្រុមការងារយេនឌ័រក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
***************

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
លេខ : ១៤ ណសណ

ភ្នំពេញ,ថ្ងៃទី ១១ ខែ [illegible] ឆ្នាំ ២០០៥

**សេចក្តីសំរេច**

**ស្តីពី**

**ការបង្កើតក្រុមការងារយេនឌ័ររបស់**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**************

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកម / ១១៨៩ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកម / ០៦៩៩ / ០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើប្រាស់ ស្តីពីការ បង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងរៀបចំ ដែនដីនគរូបនីយកម្ម និងសំណង់

-តាមការចាំបាច់របស់ក្រសួង

**សំរេច**

**ប្រការ១** : បង្កើតក្រុមការងារយេនឌ័រ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលមានសមាសភាពដូចខាងក្រោម :

| | | | | | |
|---|---|---|---|---|---|
| ១- | ឯកឧត្តម | កើត | សារ៉េត | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២- | លោកស្រី | អ៊ូ | វីឌី | អគ្គនាយករង នៃនាយកដ្ឋានរៀបចំដែនដី | អនុប្រធាន |
| ៣- | លោកស្រី | យី | ឆេង | ប្រធាននាយកដ្ឋានបុគ្គលិក | អនុប្រធានទទួលបន្ទុកអចិន្ត្រៃយ៍ |
| ៤- | លោកស្រី | ឆន់ | ភានី | អនុប្រធាននាយកដ្ឋានរដ្ឋបាល | សមាជិក |
| ៥- | លោក | សារេត | បូរាមី | អនុប្រធាននាយកដ្ឋានស្រាវជ្រាវ និងបទប្បញ្ញត្តិ | សមាជិក |
| ៦- | លោក | អេ | ប៊ុនធឿន | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការវិនិយោគ និងទំនាក់ទំនងអន្តរជាតិ | សមាជិក |
| ៧- | លោក | ជុំ | ចាន់ថា | អនុប្រធាននាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់ | សមាជិក |
| ៨- | លោក | ហេ | សូផាន់ណារ៉ា | អនុប្រធាននាយកដ្ឋានគ្រប់គ្រងដីធ្លី | សមាជិក |
| ៩- | លោកស្រី | ម៉ៅ | ឧស្សាហ៍ | ប្រធានការិ. នៃអគ្គនាយកដ្ឋានរៀបចំដែនដី | សមាជិក |
| ១០- | លោកស្រី | ពូច | ចាន់មុនី | អនុ.ការិ. នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ | សមាជិក |
| ១១- | លោកស្រី | ពូន | ប៊ុន | អនុ.ការិ. នៃអគ្គនាយកដ្ឋានសំណង់ | សមាជិក លេខាធិការ |

**ប្រការ២ :** ក្រុមការងារយេនឌ័រ មានភារកិច្ច និងតួនាទីដូចខាងក្រោម :

-សំរបសំរួលសហការ និងស្វែងរកការគាំទ្រថវិកា និងបច្ចេកទេសពីបណ្តាស្ថាប័នពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដើម្បីលើកកំពស់ការងារយេនឌ័រ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

-ផ្សព្វផ្សាយ និងបណ្តុះបណ្តាលធនធានមនុស្សផ្នែកយេនឌ័ររបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ទាំងនៅថ្នាក់ជាតិ និងតាមបណ្តាខេត្ត-ក្រុង ។

-កសាងផែនការ សកម្មភាព ដែលពាក់ព័ន្ធនិងការងារយេនឌ័រ ប្រចាំឆ្នាំ។

-បញ្ជ្រាបនូវទស្សនៈយេនឌ័រក្នុងគ្រប់កម្មវិធីអភិវឌ្ឍន៍នានារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

-ត្រួតពិនិត្យ និងវាយតំលៃនូវរាល់សកម្មភាពដែលបានអនុវត្តពាក់ព័ន្ធនឹងការងារយេនឌ័រ ។

**ប្រការ៣ :** នាយខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន គ្រប់ប្រធាននាយកដ្ឋានពាក់ព័ន្ធ ឯកឧត្តម និងអស់លោក លោកស្រីដូចមានរាយនាមក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។ ៤/៸

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** ៤/

អ៊ឹម ឈុនលឹម

<u>កន្លែងទទួល</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងកិច្ចការនារី

-ក្រុមប្រឹក្សាជាតិដើម្បីស្ត្រី

-គ្រប់ស្ថាប័នពាក់ព័ន្ធ ( ដើម្បីជូនជ្រាប )

-ដូចប្រការ៣ ( ដើម្បីអនុវត្ត )

-ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ ៣៖

# តារាងម៉ាទ្រីកផែនការយុទ្ធសាស្ត្រ ឆ្នាំ ២០០៨-២០១០

| ការពិចារណា | លទ្ធផលរំពឹងទុក | សកម្មភាព | ធនធាន |
|---|---|---|---|
| **គោលដៅទី១: ការកើនឡើងនូវការយល់ដឹងអំពីទស្សនៈយេនឌ័រ និងការវិភាគយេនឌ័ររបស់បណ្តាញការងារយេនឌ័រ និងមន្ត្រីក្រសួងនៅគ្រប់ខេត្ត-ក្រុង។** | | | |
| គោលបំណងទី ១- បង្កើនការយល់ដឹងអំពីទស្សនៈយេនឌ័រ ការវិភាគយេនឌ័រ និងការបញ្ជ្រាបយេនឌ័រ ដល់បណ្តាញការងារយេនឌ័រ នៅថ្នាក់កណ្តាល និងថ្នាក់ក្រោមជាតិ | ១.១.១ ក្រុមការងារយេនឌ័រថ្នាក់ខេត្តក្រុងត្រូវបានបង្កើត<br>**សូចនាករ:**<br>១. បញ្ជីរាយនាមសមាជិកក្រុមការងារថ្នាក់ខេត្តក្រុង | ១. រៀបចំសេចក្តីណែនាំដល់មន្ទីរខេត្តក្រុងក្នុងការបង្កើតក្រុមការងារយេនឌ័រ | |
| | ១.១.២ បណ្តាញការងារយេនឌ័របានយល់ច្បាស់អំពីទស្សៈយេនឌ័រ និងមានសមត្ថភាពគ្រប់គ្រាន់ដើម្បីធ្វើការបញ្ជ្រាបយេនឌ័រនៅក្នុងវិស័យដីធ្លី នគរូបនីយកម្ម និងសំណង់<br>**សូចនាករ:**<br>១. វគ្គបណ្តុះបណ្តាលអំពីទស្សនៈយេនឌ័រ ការវិភាគយេនឌ័រ និងការបញ្ជ្រាបយេនឌ័រ | ១. ផ្តល់ការបណ្តុះបណ្តាលអំពីទស្សនៈយេនឌ័រ ការវិភាគយេនឌ័រ និងការបញ្ជ្រាបយេនឌ័រ | |
| | ១.១.៣ បណ្តាញការងារយេនឌ័រក្រសួង បានរៀនសូត្របទពិសោធន៍ពីគ្នាទៅវិញទៅមកអំពីការបញ្ជ្រាបយេនឌ័រនៅក្នុងវិស័យដីធ្លី<br>**សូចនាករ:**<br>១. ចំនួនទស្សនៈកិច្ចសិក្សា | ១. រៀបចំទស្សនៈកិច្ចសិក្សាដើម្បីផ្លាស់ប្តូរបទពិសោធន៍ | |
| គោលបំណងទី ២- បង្កើនការយល់ដឹងអំពីទស្សនៈយេនឌ័រដល់មន្ត្រីក្រសួងនៅគ្រប់លំដាប់ថ្នាក់ | ១.២.១ មន្ត្រីរាជការនៃក្រសួងមានចំណេះដឹងមូលដ្ឋានអំពីយេនឌ័រ និងការរៀបចំទិន្នន័យបែងចែកតាមភេទ<br>**សូចនាករ:** | ១. រៀបចំកម្មវិធីបណ្តុះបណ្តាលមូលដ្ឋានអំពីយេនឌ័រ និងការចងក្រងទិន្នន័យបែងចែកតាមភេទ<br>២. ផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីក្រសួងគ្រប់ខេត្តក្រុង | |

| | | | |
|---|---|---|---|
| | ១. ឯកសារសំរាប់ការបណ្តុះបណ្តាល<br>២. ចំនួនវគ្គបណ្តុះបណ្តាល | | |
| | ១.២.២ ថ្នាក់ដឹកនាំក្រសួងគាំទ្រកាន់តែខ្លាំងក្លាដល់ការងារបញ្ជ្រាបយេនឌ័រ<br>**សូចនាករៈ**<br>១. ចំនួនសិក្ខាសាលាផ្សព្វផ្សាយដល់ថ្នាក់ដឹកនាំក្រសួង | ១. រៀបចំសិក្ខាសាលាបំផុសស្មារតី និងផ្សព្វផ្សាយអំពីទស្សនៈយេនឌ័រដល់ថ្នាក់ដឹកនាំក្រសួង | |
| **គោលដៅទី២: ចំនួនស្ត្រីនៅក្នុងតួនាទីថ្នាក់ដឹកនាំមានការកើនឡើង។** | | | |
| គោលបំណងទី ១- បង្កើនការជ្រើសរើសមន្ត្រីជាស្ត្រីឱ្យចូលបំរើការងារនៅក្នុងក្រសួង | ២.១.១ តំណាងមន្ត្រីជាស្ត្រីនៅគ្រប់ថ្នាក់នៃក្រសួងបានកើនឡើងពី ១២ ភាគរយ ដល់ ១៥ភាគរយ<br>**សូចនាករៈ**<br>១. សេចក្តីសម្រេចក្នុងការបង្កើតគណៈកម្មការជ្រើសរើស មានបញ្ចូលតំណាងក្រុមការងារយេនឌ័រ<br>២. ភាគរយមន្ត្រីជាស្ត្រីនៅក្នុងក្រសួង | ១. តំណាងក្រុមការងារយេនឌ័រត្រូវចូលរួមនៅក្នុងគណៈកម្មការជ្រើសរើស<br>២. ផ្តល់អាទិភាពបេក្ខនារីដែលមានសមត្ថភាពប្រហាក់ប្រហែលនឹងបុរស នឹងត្រូវបានជ្រើសរើសឱ្យចូលបំរើការងារក្នុងមន្ត្រីរាជការ | |
| គោលបំណងទី ២-បង្កើនសមត្ថភាពដល់មន្ត្រីជាស្ត្រី | ២.២.១ មន្ត្រីជាស្ត្រីគ្រប់លំដាប់ថ្នាក់ទទួលបានការបណ្តុះបណ្តាល និងអាចប្រកបការងារដោយប្រសិទ្ធភាពខ្ពស់<br>**សូចនាករៈ**<br>១. ចំនួនវគ្គបណ្តុះបណ្តាលដែលមន្ត្រីជាស្ត្រីទទួលបាន | ១. ផ្តល់ការបណ្តុះបណ្តាលខ្លីៗអំពី ការធ្វើផែនការ ការលើកសំណើសុំថវិកា ជំនាញស្វែងរកការគាំទ្រមតិ ជំនាញភាពជាអ្នកដឹកនាំ ការគ្រប់គ្រង ភាសាអង់គ្លេស និងជំនាញកុំព្យូទ័រ | |
| | ២.២.,២ អត្រាចូលរួមរបស់ស្ត្រីនៅក្នុងវគ្គបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស បានកើនឡើងដល់ ៤០ភាគរយ<br>**សូចនាករៈ**<br>១. អត្រាចូលរួមរបស់ស្ត្រីនៅក្នុងវគ្គបណ្តុះបណ្តាល | ១.ផ្តល់ឱកាស និងលើកទឹកចិត្តដល់ស្ត្រីឱ្យចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស យ៉ាងតិច ១០-១៥ភាគរយនៃសិក្ខាកាមសរុប | |
| គោលបំណងទី ៣- បង្កើនចំនួនស្ត្រីនៅក្នុងតួនាទីថ្នាក់ដឹកនាំ | ២.៣.១ តំណាងស្ត្រីចាប់ពីថ្នាក់ការិយាល័យនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តក្រុង កើនឡើងពី ១០ភាគរយ ដល់ ២០ភាគរយ | ១. ធានាថាគោលការណ៍តែងតាំងមន្ត្រីរាជការដោយឆ្លើយតបទៅនឹងយេនឌ័រ១០-២០ភាគរយ ដើម្បីផ្តល់ឱកាសឱ្យស្ត្រីដែលមាន | |

| | | | |
|---|---|---|---|
| | នៃចំនួនមន្ត្រីមានសមត្ថភាពសរុបដែលស្មើតែងតាំង<br><br>**សូចនាករ:**<br>១. គោលការណ៍តែងតាំងមន្ត្រីរាជការដោយឆ្លើយតបទៅនឹងយេនឌ័រ<br>២. តំណាងស្ត្រីចាប់ពីថ្នាក់ការិយាល័យនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តក្រុងកើនឡើង | សមត្ថភាពសមមូលនឹងបុរសនូវតួនាទីនៅក្នុងជួរថ្នាក់ដឹកនាំគ្រប់ថ្នាក់របស់ក្រសួង | |
| **គោលដៅទី៣: ការចុះឈ្មោះ និងផ្តល់បណ្ណកម្មសិទ្ធិរួមគ្នារវាងប្តី និងប្រពន្ធ ត្រូវបានបន្ត និងបង្កើនការយកចិត្តទុកដាក់។** | | | |
| គោលបំណងទី ១- បណ្តុះបណ្តាលមន្ត្រីក្រុមការងារចុះបញ្ជីដីធ្លី និងគណៈកម្មការសុរិយោដី អំពីយេនឌ័រនិងដីធ្លី | ៣.១.១ បញ្ហាយេនឌ័រនៅក្នុងការចុះបញ្ជីដីធ្លី ត្រូវបានយកចិត្តទុក និងគិតគូរជាប់ជាប្រចាំពីក្រុមការងារចុះបញ្ជីដីធ្លី និងមន្ត្រីគណៈកម្មការសុរិយោដី<br>**សូចនាករ:**<br>១. កម្មវិធីបណ្តុះបណ្តាល<br>២. ចំនួនវគ្គបណ្តុះបណ្តាល | ១. រៀបចំកម្មវិធីបណ្តុះបណ្តាលអំពីបញ្ហាយេនឌ័រ នៅក្នុងការចុះបញ្ជីដីធ្លី និងការប្រមូលទិន្នន័យបែងចែកតាមភេទ<br>២. ធ្វើការបណ្តុះបណ្តាលដល់ក្រុមការងារចុះបញ្ជីដីធ្លី និង មន្ត្រីគណៈកម្មការសុរិយោដី | |
| គោលបំណងទី ២- ផ្តល់ព័ត៌មានដល់សហគមន៍អំពីការចុះដីធ្លី ផ្តោតការយកចិត្តទុកដាក់ជាពិសេសដល់ស្ត្រី | ៣.២.១ ស្ត្រីនៅក្នុងសហគមន៍ចូលរួមបានច្រើននៅពេលប្រកាសផ្សព្វផ្សាយព័ត៌មាន និងបានជ្រួតជ្រាបអំពីច្បាប់ភូមិបាល<br>**សូចនាករ:**<br>១. អត្រាចូលរួមរបស់ស្ត្រីនៅក្នុងសហគមន៍<br>២. ចំនួនវគ្គផ្សព្វផ្សាយអំពីច្បាប់ភូមិបាល | ១. រៀបចំការប្រជុំ ឬប្រកាសផ្សព្វផ្សាយព័ត៌មានដល់សហគមន៍អំពីការចុះបញ្ជីដីធ្លី<br>២. លើកទឹកចិត្តដល់ស្ត្រីនៅតាមសហគមន៍ឱ្យចូលរួមបានច្រើន<br>៣. ធ្វើការផ្សព្វផ្សាយពី ច្បាប់ភូមិបាល ដោយផ្តោតជាពិសេសអំពីសិទ្ធកម្មសិទ្ធដីធ្លី ដោយសហការជាមួយក្រុមការងារចុះបញ្ជីដីធ្លី និងគណៈកម្មការសុរិយោដី | |
| គោលបំណងទី ៣- ចូលរួមតាមដានជាប់ជាប្រចាំនូវដំណើរការចុះបញ្ជីដីធ្លី ដើម្បីបង្កើនការចុះឈ្មោះប្តីប្រពន្ធរួមគ្នា | ៣.៣.១ របាយការណ៍វឌ្ឍនភាពបានបង្ហាញពីការយកចិត្តទុកដាក់របស់ក្រុមការងារ នៅក្នុងការចុះបញ្ជីដីធ្លីរួមគ្នា<br>**សូចនាករ:**<br>១. របាយការណ៍វឌ្ឍនភាព | ១. សហការជាមួយគណៈកម្មការសុរិយោដី និងក្រុមការងារចុះបញ្ជីដីធ្លី ក្នុងការតាមដានការចុះបញ្ជីដីធ្លី<br>២. ចុះពិនិត្យតាមដាននៅតាមមូលដ្ឋាន | |

| | | | |
|---|---|---|---|
| | ២. ចំនួនការចុះតាមដាននៅតាមមូលដ្ឋាន | | |
| **គោលដៅទី៤: ស្ត្រីជាមេគ្រួសារក្រីក្រ ស្ត្រីមេម៉ាយ និងស្ត្រីដែលជាអ្នករកចំណូលចិញ្ចឹមគ្រួសារ ត្រូវបានផ្តល់អាទិភាពក្នុងការទទួលបានដីសម្បទានសង្គមកិច្ច។** | | | |
| គោលបំណងទី ១- បណ្តុះបណ្តាលមន្ត្រីអនុវត្តគំរោងបែងចែកដីសម្បទានសង្គមកិច្ច អំពីបញ្ហាយេនឌ័រនៅក្នុងការបែងចែកដីធ្លី | ៣.១.១ បញ្ហាយេនឌ័រនៅក្នុងការបែងចែកដីធ្លី ត្រូវបានយកចិត្តទុកនិងគិតគូរជាប់ជាប្រចាំពីក្រុមការងារ<br>**សូចនាករ:**<br>១. កម្មវិធីបណ្តុះបណ្តាល<br>២. ចំនួនវគ្គបណ្តុះបណ្តាល | ១. រៀបចំកម្មវិធីបណ្តុះបណ្តាលអំពីបញ្ហាយេនឌ័រនៅក្នុងការបែងចែកដីធ្លី និងការប្រមូលទិន្នន័យបែងចែកតាមភេទ<br>២. ធ្វើការបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តគំរោង | |
| គោលបំណងទី ២- ធានាថាស្ត្រីជាមេគ្រួសារក្រីក្រ ស្ត្រីមេម៉ាយ និងស្ត្រីដែលជាអ្នករកចំណូលចិញ្ចឹមគ្រួសារ ត្រូវបានផ្តល់អាទិភាពក្នុងការទទួលបានដីសម្បទានសង្គមកិច្ច | ៣.២.១ ស្ត្រីនៅក្នុងសហគមន៍ចូលរួមបានច្រើននៅពេលប្រកាសផ្សព្វផ្សាយព័ត៌មាន<br>**សូចនាករ:**<br>១. អត្រាចូលរួមរបស់ស្ត្រីនៅក្នុងពេលផ្សព្វផ្សាយព័ត៌មាន | ១. រៀបចំការប្រជុំ ឬប្រកាសផ្សព្វផ្សាយព័ត៌មានដល់សហគមន៍អំពីការចុះបញ្ជីដីធ្លី<br>២. លើកទឹកចិត្តដល់ស្ត្រីនៅតាមសហគមន៍ឱ្យចូលរួមបានច្រើន | |
| | ៣.២.២ ស្ត្រីជាមេគ្រួសារក្រីក្រ ស្ត្រីមេម៉ាយ និងស្ត្រីដែលជាអ្នករកចំណូលចិញ្ចឹមគ្រួសារ ទទួលបានដីសម្បទានសង្គមកិច្ចក្នុងអត្រាមួយសមស្រប<br>**សូចនាករ:**<br>១. អត្រាស្ត្រីជាមេគ្រួសារក្រីក្រ ស្ត្រីមេម៉ាយ និងស្ត្រីដែលជាអ្នករកចំណូលចិញ្ចឹមគ្រួសារ ដែលទទួលបានដីសម្បទានសង្គមកិច្ច | ១. សហការជាមួយមន្ត្រីអនុវត្តគំរោងក្នុងការចូលរួមវាយតម្លៃលក្ខណៈវិនិច្ឆ័យរបស់គ្រួសារដែលដាក់ពាក្យសុំ | |
| | ៣.២.៣ ស្ត្រី និងកុមារទទួលបាននូវសេវាគាំទ្រផ្សេងៗដូចជាវិស័យកសិកម្ម សុខាភិបាល និងអប់រំជាដើម<br>**សូចនាករ:**<br>១. អត្រាស្ត្រីដែលទទួលបានការបណ្តុះបណ្តាលជំនាញកសិកម្ម<br>២. អត្រាស្ត្រីដែលទទួលបានសេវាសុខាភិបាល | ១. រៀបចំការប្រជុំ ឬសិក្ខាសាលាដល់មន្ត្រីអនុវត្តគំរោង ដោយផ្តោតការពិភាក្សាលើសេវាគាំទ្រនានាដល់ស្ត្រីនិងកុមារ<br>២. សហការជាមួយមន្ត្រីអនុវត្តគំរោងក្នុងការជ្រើសរើសអ្នកទទួលផលពីសេវាគាំទ្រផ្សេងៗ | |

| | | | |
|---|---|---|---|
| | ៣.អត្រាកុមារដែលបានចុះឈ្មោះចូលរៀន និងអត្រាបោះបង់ការសិក្សា | | |
| គោលបំណងទី ៣- ចូលរួមតាមដានជាប់ជាប្រចាំនូវការអនុវត្តកម្មវិធីបែងចែកដីសម្បទានសង្គមកិច្ច | ៣.៣.១ របាយការណ៍វឌ្ឍនភាពបានបង្ហាញពីការយកចិត្តទុកដាក់របស់ក្រុមការងារដល់ស្ត្រីក្រីក្រ ស្ត្រីជាមេគ្រួសារ ស្ត្រីមេម៉ាយ និងស្ត្រីដែលជាអ្នករកចំណូលចិញ្ចឹមគ្រួសារ<br>**សូចនាករ:**<br>១. របាយការណ៍វឌ្ឍនភាព<br>២. ចំនួនការចុះតាមដាននៅតាមមូលដ្ឋាន | ១. សហការជាមួយក្រុមការងារអនុវត្តគំរោង ក្នុងការតាមដាននូវការបែងចែកបញ្ជីដីធ្លីសង្គមកិច្ច<br>២. ចុះពិនិត្យតាមដាននៅតាមមូលដ្ឋានគោលដៅ | |
| **គោលដៅទី ៥: ស្ត្រីត្រូវបានធានានូវការទទួលបានសិទ្ធិការពារខាងផ្លូវច្បាប់នៅពេលមានបញ្ហាវិវាទដីធ្លី។** | | | |
| គោលបំណងទី ១- យកចិត្តទុកដាក់ចំពោះពាក្យបណ្តឹងដែលមានស្ត្រីជាដើមបណ្តឹង ឬជាចុងចោទ និងការដោះស្រាយ | ៥.១, ករណីបណ្តឹងត្រូវបានដោះស្រាយយ៉ាងសុក្រឹត្យ និងយុត្តិធម៌<br>**សូចនាករ:**<br>១. ចំនួនវគ្គផ្សព្វផ្សាយដល់គណៈកម្មការដោះស្រាយវិវាទដីធ្លី និង អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី<br>២. ករណីបណ្តឹង និងការទទួលបានការការពារខាងផ្លូវច្បាប់ ដោយការជួយចង្អុលបង្ហាញនូវមេធាវីដែលពុំគិតកំរៃសេវាកម្មជាដើម | ១. ធ្វើការផ្សព្វផ្សាយដល់គណៈកម្មការសុរិយោដី និង អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី ឱ្យយកចិត្តទុកដាក់ដល់ករណីបណ្តឹងរបស់ស្ត្រី<br>២. សម្របសម្រួលដោយធានាថាស្ត្រីទទួលបានសិទ្ធិការពារខាងផ្លូវច្បាប់ ដូចជាការជួយស្វែងរកមេធាវីការពារជាដើម | |
| គោលបំណងទី ២- លើកទឹកចិត្តដល់ស្ត្រីនៅតាមមូលដ្ឋានឱ្យធ្វើជាជនបង្គោលក្នុងការអប់រំផ្សព្វផ្សាយ និងស៊ើបអង្កេត | ៥.២, ស្ត្រីជាជនបង្គោលនៅតាមសហគមន៍មានចំនួនកើនឡើង<br>**សូចនាករ:**<br>១. ចំនួនស្ត្រីជាជនបង្គោលនៅតាមសហគមន៍ | ១. ជ្រើសរើសស្ត្រីនៅតាមសហគមន៍ជាជនបង្គោល<br>២. សហការក្នុងការចងក្រងទិន្នន័យបែងចែកតាមភេទអំពីជនបង្គោលនៅតាមសហគមន៍ | |
| | ៥.២.២ សហគមន៍បានយល់កាន់ច្បាស់ពីច្បាប់ភូមិបាល ហើយករណីបណ្តឹងមានការថយចុះពីមួយឆ្នាំទៅមួយឆ្នាំ<br>**សូចនាករ:**<br>១. ចំនួនវគ្គផ្សព្វផ្សាយអំពីច្បាប់ភូមិបាល | ១. ចូលរួមផ្សព្វផ្សាយច្បាប់ភូមិបាលតាមគ្រប់រូបភាព | |

| | | | |
|---|---|---|---|
| | ២. ករណីបណ្តឹងដែលទទួលបាន | | |
| **គោលដៅទី ៦ : ការចូលរួមរបស់ស្ត្រីក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានការកើនឡើង។** | | | |
| គោលបំណង ទី១ : បង្កើនការយល់ដឹង និងការចូលរួមរបស់ស្ត្រី លើការងារគ្រប់គ្រងការប្រើប្រាស់ដីធ្លីឱ្យមានចីរភាព | ៦.១.១ បរិមាណនៃការចូលរួមរបស់ស្ត្រីក្នុងការផ្តល់មតិ លើគំរោងកសាងផែនការប្រើប្រាស់ដីធ្លី ក៏ដូចជាផែនទីប្រើប្រាស់ដី និងផែនទីយុទ្ធសាស្ត្រអភិវឌ្ឍន៍ដីគ្រប់ខ្នាត កើនឡើង<br>**សូចនាករ:**<br>១. លទ្ធផលនៃការប្រជុំពិនិត្យផែនការ/ផែនទីប្រើប្រាស់ដីធ្លី ចំនួនលើក និងវត្តមាននៃការចូលរួមក្នុង១លើក១ | ១.ធ្វើការអប់រំផ្សព្វផ្សាយ អំពីគោលបំណង ផលប្រយោជន៍គោលការណ៍ និងនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដី ឬផែនទីកំណត់តំបន់អភិវឌ្ឍន៍នានា តាមគ្រប់នីតិវិធី ដើម្បីឱ្យប្រជាជន ពិសេសស្ត្រីបានជ្រួតជ្រាប និងចូលរួម | |
| គោលបំណងទី២ : លើកកំពស់តួនាទីរបស់ស្ត្រីក្នុងការងារអភិវឌ្ឍផ្នែកសំណង់ និងនគរូបនីយកម្ម ដើម្បីរក្សា និងអភិរក្សបាននូវបរិស្ថាន សោភណភាព បេតិកភ័ណ្ឌ និងស្ថាបត្យកម្មជាតិ | ៦.២.១-ស្ត្រីជាមេគ្រួសារ ឬជាសហព័ទ្ធត្រូវបានលើកទឹកចិត្តឱ្យចុះហត្ថលេខា ឬផ្តិតមេដៃលើសំណើសុំសាងសង់ លើគំរោងប្លង់ស្ថាបត្យកម្មនាន<br>**សូចនាករ:**<br>១. ចំនួនប្លង់ដែលផ្តល់លិខិតអនុញ្ញាតសាងសង់ ដោយបញ្ជាក់ពីសមភាគីនៃសហព័ទ្ធដែលពាក់ព័ន្ធនឹងសំណើសុំសាងសង់ | ១. ជំរុញការណែនាំដល់ជំនាញគ្រប់ថ្នាក់ឱ្យយកចិត្តទុកដាក់អនុវត្តគោលការណ៍នៃការចូលរួមរបស់ស្ត្រី និងបុរសជាសហព័ទ្ធ ដែលពាក់ព័ន្ធនឹងសំណើសុំសាងសង់ និងគំរោងប្លង់ស្ថាបត្យកម្ម | |
| | ៦.២.២- កម្មករសំណង់ ទាំងសេរី ទាំងអាជីព ពិសេសស្ត្រី ត្រូវបានធានាគាំពារស្របតាមប្រកាសអន្តរក្រសួងស្តីពីការធានារ៉ាបរងសុវត្ថិភាពការដ្ឋាន<br>**សូចនាករ:**<br>១. ចំនួនការដ្ឋានដែលបានបើក និងការបញ្ជាក់ពីចំនួនពលករសំណង់ស្រីប្រុស ដែលការដ្ឋាននីមួយៗកំពុងដំណើរការ | ១. ណែនាំ និងផ្សព្វផ្សាយដល់គ្រប់ក្រុមហ៊ុន សហគ្រាស និងក្រុមម៉ៅការសំណង់ យកចិត្តទុកដាក់អនុវត្តប្រកាសអន្តរក្រសួង ស្តីពីការធានារ៉ាប់រងសុវត្ថិភាពការដ្ឋាន ពិសេសចំពោះកម្មករជានារីដែលជាភេទងាយរងគ្រោះថ្នាក់ | |

# ឧបសម្ព័ន្ធ ៤: បញ្ជីត្រួតពិនិត្យសំរាប់ការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធី ឬ គំរោង

១- សំណួរអំពីការវិភាគយេនឌ័រនៅពេលចាប់ផ្តើមរៀបចំគំរោង

តើការវិភាគយេនឌ័រត្រូវបានគេប្រតិបត្តិឬទេ? បើសិនជាមាន:

- វិភាគដោយរបៀបណា? តើនរណាវិភាគ?
- តើផលប្រយោជន៍អ្វីខ្លះដែលបុរស និង ស្ត្រីទទួលបាន? តើបុរស និង ស្ត្រីចូលរួមអនុវត្តគំរោងបានទទួលផលអ្វីខ្លះ?
- តើការវិភាគយេនឌ័រនេះមានគុណភាពល្អត្រឹមត្រូវឬទេ?
- បើសិនជាគ្មានការវិភាគយេនឌ័រ:
- ហេតុអ្វីបានពុំមានការវិភាគយេនឌ័រ? តើការវិភាគនេះនឹងធ្វើឡើងនៅពេលណា?
- តើការវិភាគនេះនឹងផ្តោតលើអ្វីខ្លះ?
- តើបច្ចុប្បន្ននេះមានព័ត៌មានអ្វីខ្លះ?

២- សំណួរអំពីការប្រើប្រាស់លទ្ធផលនៃការវិភាគយេនឌ័រ

- តើលទ្ធផលនៃការវិភាគត្រូវបានបញ្ចូលទៅក្នុងការតាក់តែងគំរោងដោយរបៀបណា?
- តើលទ្ធផលនៃការវិភាគត្រូវបានបញ្ចូលទៅក្នុងការវិភាគបញ្ហាឬទេ?
- តើយុទ្ធសាស្ត្រដែលរៀបចំឡើងមានបញ្ចូលយុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហាយេនឌ័រ?
- តើសកម្មភាពអ្វីខ្លះនឹងត្រូវបានរៀបចំឡើង ដើម្បីបញ្ហាយេនឌ័រដែលបានកំណត់ឡើងនៅតាមថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងក្នុងរយៈពេលខ្លី និងរយៈពេលវែង? តើសកម្មភាពទាំងនោះនឹងត្រូវដាក់បញ្ចូលជាសកម្មភាពរបស់គំរោងដែរឬទេ?
- តើការប៉ាន់ប្រមាណនេះរួមបញ្ចូលសូចនាករដើម្បីតាមដាន និងប៉ាន់ប្រមាណពីលទ្ធផលលើស្ត្រី និងប្រជាជនក្រីក្រឬទេ?
- តើលទ្ធផលនៃការវិភាគយេនឌ័រមានព័ត៌មានគ្រប់គ្រាន់ដើម្បីប្រើប្រាស់ជាទិន្នន័យមូលដ្ឋាន និងទិន្នន័យបញ្ចប់គំរោងដែរឬទេ?

៣- បុគ្គលិក និង ការគ្រប់គ្រងគំរោង

- តើការជ្រើសរើសបុគ្គលិកឆ្លុះបញ្ចាំងពីតុល្យភាព និង សមធម៌យេនឌ័រដែរឬទេ?
- តើបុគ្គលិកជាស្ត្រីអាចចូលរួមក្នុងការសំរេច និង ការគ្រប់គ្រងគំរោងឬកម្មវិធីក្នុងកំរិតណា?
- តើគោលនយោបាយធនធានមនុស្សរបស់គំរោងមានចែងអំពីច្បាប់មាតុភាព និង បិតុភាពដែរឬទេ?
- តើបុគ្គលិករបស់គំរោងត្រូវការការបណ្តុះបណ្តាលអំពីយេនឌ័រឬទេ?
- តើគំរោងនឹងរៀបចំការបណ្តុះបណ្តាលសំរាប់ការបញ្ចូលបញ្ហាយេនឌ័រទៅក្នុងការរៀបចំផែនការ និងការអនុវត្តន៍ដែរឬ?

៤- ការវាយតំលៃពាក់កណ្តាល និង ចុងបញ្ចប់នៃគំរោង

- តើការវាយតំលៃនឹងផ្តោតលើសូចនាករយេនឌ័រនៅក្នុងគំរោងដើម្បីធានាថាគំរូវការ ផលប្រយោជន៍ និងអ្នកទទួលផលផ្សេងៗ ទទួលបានប្រយោជន៍ដូចគ្នា?
- តើនឹងមានការវាយតំលៃដាច់ដោយឡែក ដើម្បីដឹងវាស់ស្ទង់ពីលទ្ធផលទាក់ទងនឹងយេនឌ័រ និងប៉ាន់ប្រមាណពីផលប៉ះពាល់លើស្ត្រី និងក្រុមប្រជាជនក្រីក្រដូចដែលបានគ្រោងទុកឬអាចផ្តល់ជាអនុសាសន៍បាន?

៥- ការគាំទ្រការបញ្ជ្រាបយេនឌ័រថ្នាក់ជាតិ

- តើគំរោង ឬកម្មវិធី នឹងគាំទ្រការបញ្ជ្រាបយេនឌ័រនៅក្នុងផែនការតាមវិស័យដូចជាការអនុវត្តន៍ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ក្រសួងពាក់ព័ន្ធ?

៦- សំណួរទាក់ទងថវិកា

- តើថវិកាដែលលើកឡើងគ្រប់គ្រាន់សំរាប់ការវិភាគយេនឌ័រ ការវាយតំលៃការស្រាវជ្រាវឬទេ?
- តើថវិកាដែលស្នើឡើងគ្រប់គ្រាន់សំរាប់ការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកយេនឌ័រដែរឬទេ?
- តើថវិកាដែលស្នើឡើងគ្រប់គ្រាន់សំរាប់ការកសាងសមត្ថភាពក្នុងការបញ្ជ្រាបយេនឌ័រដែរឬទេ?

(កែសំរួលពី UNDP Cambodia Gender Initiative 2007)

## ឧបសម្ព័ន្ធ ៥: វាក្យសព្ទបច្ចេកទេសយេនឌ័រ

- **យេនឌ័រ:** គឺសំដៅយកតួនាទី ឥរិយាបថ និង តំលៃនានាដែលវប្បធម៌នានា និង សង្គមដាក់កំណត់ឱ្យបុរស និង ស្ត្រី អនុវត្តដោយឡែកពីគ្នាពីតួនាទី ឥរិយាបថ និង គុណតំលៃទាំងនេះកំណត់នូវអាកប្បកិរិយា និង ទំនាក់ទំនងរវាង បុរស និង ស្ត្រី។ តួនាទី ឥរិយាបថ និង គុណតំលៃទាំងនេះត្រូវបានបង្កើតឡើង និង ថែរក្សាដោយស្ថាប័ន សង្គមនានាដូចជា គ្រួសារ រដ្ឋាភិបាល សហគមន៍ សាលារៀន វត្តអារាម និង សារព័ត៌មាន។
- **ភេទ:** សំដៅលើភាពខុសគ្នាតាមធម្មជាតិ និង លក្ខណៈជីវសាស្ត្រដែលកំណត់មនុស្សណាមួយថាជាបុរស ឬជាស្ត្រី។ ភេទសំដៅយកលក្ខណៈរូបរាងកាយ និង សរីរាង្គរបស់មនុស្សម្នាក់ៗ។
- **ការយល់ដឹងពីយេនឌ័រ:** ការយល់ដឹងអំពីភាពខុសគ្នារវាងបុរស និង ស្ត្រីដែលសង្គមបានកំណត់ឡើងដោយឈរលើ ចំណេះដឹងស្តីពីអាកប្បកិរិយានានាដែលជះឥទ្ធិពលទៅលើសមត្ថភាពនៃការទទួលបាន និង ការគ្រប់គ្រាន់ធនធាន ឱកាស និង ផលប្រយោជន៍។
- **គំលាតយេនឌ័រ:** ជាគំលាតរវាងបុរស និង ស្ត្រីនៅក្នុងការចូលរួម ការទទួលបាលសិទ្ធិ ឱកាស និង ការគ្រប់គ្រងលើ ធនធាន និង ផលប្រយោជន៍នៅក្នុងវិស័យណាមួយ។
- **សមភាពយេនឌ័រ:** ជាភាពគ្មានការរើសអើង ដោយយកភេទរបស់បុគ្គលមកធ្វើជាមូលដ្ឋានក្នុងការបែងចែកធនធាន ឬការទទួលផលប្រយោជន៍ និង សេវាកម្មនានា។ សមភាពយេនឌ័រអាចវាស់វែងបាន ដោយពិនិត្យលើកាលានុវត្តភាព ស្មើគ្នា ឬ ការទទួលផលប្រយោជន៍ស្មើគ្នា។
- **សមធម៌យេនឌ័រ:** ជាដំណើរការនៃការប្រព្រឹត្តដោយយុត្តិធម៌ទៅលើស្ត្រី និង បុរសដើម្បីបន្ថយគំលាតយេនឌ័រ និង ឱ្យមានសមភាពយេនឌ័រ។
- **ការវិភាគយេនឌ័រ:** សំដៅលើដំណើរការវិភាគ និង ពិនិត្យម៉ត់ចត់លើតួនាទីរបស់បុរស និង ស្ត្រី ដោយរួមបញ្ចូល បញ្ហាគន្លឹះនានាដូចជា ការបែងចែកកំលាំងពលកម្ម សកម្មភាព ផលិតកម្ម និង ការបន្តពូជ ការទទួលបាន និង ការ គ្រប់គ្រងធនធាន តំរូវការ និង ផលប្រយោជន៍ កត្តាសង្គម និង សេដ្ឋកិច្ចនានាដែលមានឥទ្ធិពលលើបុរស និង ស្ត្រី។ ការវិភាគយេនឌ័រត្រូវធ្វើឡើងនៅគ្រប់ជំហាននៃការរៀបចំផែនការ កម្មវិធី គំរោងដោយចាប់ផ្តើមពីការកំណត់អាទិ ភាព ការប្រមូលទិន្នន័យ ការរៀបចំ ការអនុវត្តន៍ ការតាមដាន និង វាយតំលៃកម្មវិធី និង គំរោង។
- **អព្យាក្រិតភាពយេនឌ័រ:** ជាទស្សនៈមិនលំអៀងចំពោះទំនាក់ទំនងយេនឌ័រ ដែលជាទូទៅមិនអាចជួយដល់ដំណើរ ការនៃការខិតខំប្រឹងប្រែងឱ្យមានសមភាពយេនឌ័រ។
- **ភាពមិនមានទស្សនៈយេនឌ័រ:** ជាការមិនទទួលស្គាល់ និង មិនយកចិត្តទុកដាក់លើបញ្ហា តំរូវការ និង ការទទួលផល ប្រយោជន៍ខុសគ្នារវាងបុរស និង ស្ត្រីក្នុងការទទួលបានធនធាន ការធ្វើសេចក្តីសំរេច និង តួនាទីខុសគ្នារវាងបុរសស្ត្រី និង កុមារាកុមារី។ គោលនយោបាយមិនមានទស្សនៈយេនឌ័រសន្និម៉ត់ថាពុំមានខុសគ្នារវាងបុរស និង ស្ត្រីទេ។
- **ការបញ្ជ្រាបយេនឌ័រ:** ជាការដាក់បញ្ចូលបញ្ហា និង តំរូវការរបស់បុរស និង ស្ត្រីទៅក្នុងការវិភាគ ការប៉ាន់ប្រមាណ និង ការតាមដានត្រួតពិនិត្យការរៀបចំ និង អនុវត្តកម្មវិធី គំរោង គោលនយោបាយ និង ច្បាប់នានា ដើម្បីធានាថា បុរស និង ស្ត្រីបានចូលរួមក្នុងការអនុវត្ត ធ្វើសេចក្តីសំរេច និង ទទួលផលប្រយោជន៍ស្មើគ្នា។

- **ការឆ្លើយតបតំរូវការយេនឌ័រ:** ជាការដោះស្រាយតំរូវការ បញ្ហា និង ផលប្រយោជន៍ខុសគ្នារវាងបុរសស្ត្រី និង កុមារាកុមារី ដើម្បីជៀសវាងការសន្និម៉ត់ថាបុរសស្ត្រី និង កុមារាកុមារីស្ថិតក្នុងស្ថានភាពដូចគ្នា។
- **ថវិកាឆ្លើយតបយេនឌ័រ:** ជាការធានាថាបញ្ហា តំរូវការ ផលប្រយោជន៍ និង ការចូលរួមរបស់បុរសស្ត្រី និង កុមារកុមារីត្រូវបានដោះស្រាយ និង ដាក់បញ្ចូលនៅពេលរៀបចំ និង វិភាជថវិកាសំរាប់ការអនុវត្តន៍កម្មវិធី គំរោង ឬ សកម្មភាពផ្សេងៗ។ ថវិកាយេនឌ័រដែលមានប្រសិទ្ធភាពត្រូវធានាថា បញ្ហាយេនឌ័រត្រូវបានវិភាគ និង ដោះស្រាយចាប់តាំងពីការរៀបចំ អនុវត្ត តាមដាន និង វាយតំលៃគំរោង និង កម្មវិធី។
- **ទិន្នន័យបែងចែកតាមភេទ:** ជាស្ថិតិដែលពិពណ៌នាពីស្ថានភាពខុសគ្នារវាងបុរសស្ត្រី និង កុមារាកុមារី ជាឧទាហរណ៍ ចំនួនមន្ត្រីរាជការជាបុរស និង ស្ត្រី ឬ ចំនួនកុមារា កុមារីកំពុងរៀននៅកំរិតបឋមសិក្សា។